ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# ផែនការយុទ្ធសាស្ត្រ
# បញ្ញាបយេនឌ័រក្នុងវិស័យអប់រំ
# ២០២១-២០២៥

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០១៦-២០២០ សម្រេចបានសមិទ្ធផលធំៗគួរឱ្យកត់សម្គាល់ ដែលបានឆ្លើយតបទៅនឹងសមភាពយេនឌ័រ និងការកសាងបរិស្ថានអប់រំ គួរជាទីមោទកៈ រួមមាន៖ ការកាត់បន្ថយគម្លាតយេនឌ័រក្នុងការទទួលបានសេវាអប់រំ ការបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ និងការបណ្តុះឥរិយាបថវិជ្ជមានរបស់សង្គមឆ្លើយតបទៅនឹងយេនឌ័រក្នុងវិស័យអប់រំ ។

ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣ ដែលសំដៅពង្រឹងសមភាពយេនឌ័រនៅគ្រប់កម្រិត និងគ្រប់វិស័យ និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ក្រសួងបានប្តេជ្ញាចិត្តលើកកម្ពស់សមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត ការបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ និងការកសាងបរិស្ថានអប់រំ និងឥរិយាបថវិជ្ជមានរបស់សង្គម ដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ២០២១-២០២៥ ត្រូវបានរៀបចំឡើងដោយផ្អែកលើវឌ្ឍនភាពនិងបញ្ហាប្រឈមនានានៃការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ២០១៦-២០២០ និងគ្របដណ្តប់លើគ្រប់អនុវិស័យ សំដៅលុបបំបាត់អំពើហិង្សា ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទគ្រប់រូបភាព ការផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ការផ្តល់ភាពអង់អាចដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រង និងដឹកនាំឱ្យកាន់តែល្អប្រសើរឡើង។ ផែនការនេះ បង្ហាញពីទំនាក់ទំនងច្បាស់លាស់រវាងគោលបំណងក្របខណ្ឌយុទ្ធសាស្ត្រ និងសកម្មភាព ដែលផ្តល់ភាពងាយស្រួលក្នុងការពិនិត្យតាមដាន និងវាយតម្លៃ រួមជាមួយនឹងយន្តការសម្រាប់ផ្តល់ព័ត៌មានត្រឡប់ និងការពិនិត្យឡើងវិញ។

ក្រសួងអប់រំ យុវជន និងកីឡាសូមកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ដែលបានចូលរួមគាំទ្រ និងរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥ ឱ្យសម្រេចបានដោយជោគជ័យ។ ក្រសួងសង្ឃឹមថាអ្នកពាក់ព័ន្ធទាំងអស់ជួយគាំទ្រ និងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានលទ្ធផលល្អ ដើម្បីអនាគតកុមារ និងយុវជនកម្ពុជាជំនាន់ក្រោយ។

ថ្ងៃ[illegible] ខែផល្គុន ឆ្នាំជូត ទោស័ក ពស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១. | **សេចក្តីផ្តើម** | ១ |
| ២. | **លទ្ធផលសម្រេចបាន ក្នុងឆ្នាំ២០១៦-២០២០** | ២ |
| ២.១ | ការបណ្តុះគរិយាបថសង្គមវិជ្ជមានចំពោះការអប់រំកុមារី និងសមភាពយេនឌ័រក្នុងចំណោមអ្នកពាក់ព័ន្ធវិស័យអប់រំ | ២ |
| ២.២ | ការបង្កើនសមភាពយេនឌ័រនៅក្នុងការអប់រំ និងការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការងារគ្រប់គ្រង | ១១ |
| ២.៣ | បញ្ហាប្រឈម | ១៦ |
| ៣. | **ចក្ខុវិស័យ** | ១៧ |
| ៤. | **បេសកកម្ម** | ១៧ |
| ៥. | **គោលបំណង** | ១៧ |
| ៦. | **ក្របខណ្ឌយុទ្ធសាស្រ្ត** | ១៧ |
| ៧ | **ផែនការសកម្មភាព** | ២៤ |
| ៧.១ | លទ្ធផលរំពឹងទុក | ២៤ |
| ៧.២ | សូចនាករ និងចំណុចដៅ | ២៤ |
| ៧.៣ | ម៉ាទ្រិកលទ្ធផល សកម្មភាព | ២៦ |
| ៧.៤ | ម៉ាទ្រិកផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១-២០២៥ | ៣៣ |
| ៨. | **ធនធានហិរញ្ញវត្ថុ** | ៥៣ |
| ៩. | **ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** | ៥៣ |

# អក្សរកាត់

| | |
|---|---|
| ក្រយឧ | ក្រុមការងារយេនឌ័រ |
| គកនក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ |
| គប | នាយកដ្ឋានគោលនយោបាយ |
| គម | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន |
| តទវ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| នក | នាយកដ្ឋាននីតិកម្ម |
| បវ | នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ |
| បស | នាយកដ្ឋានបឋមសិក្សា |
| បល | នាយកដ្ឋានបុគ្គលិក |
| បវព | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ផក | នាយកដ្ឋានផែនការ |
| ពវ | នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ |
| ពអ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| ពអស៊ | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន |
| មចទ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| មជហក | មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា |
| យវ | នាយកដ្ឋានយុវជន |
| សស | នាយកដ្ឋានសុខភាពសិក្សា |
| សណ | នាយកដ្ឋានសំណង់ |
| សទរ | នាយកដ្ឋានសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ |
| ហវ | នាយកដ្ឋានហិរញ្ញវត្ថុ |
| អកឡ | នាយកដ្ឋានអប់រំកាយ និងកីឡា |
| វអក | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា |
| វជអ | វិទ្យាស្ថានជាតិអប់រំ |
| អកត | នាយកដ្ឋានអប់រំកុមារតូច |
| អកប | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| អកស | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| អកសន | នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត |
| អគបផ | អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| អគអរ | អគ្គនាយកដ្ឋានអប់រំ |
| អគយវ | អគ្គនាយកដ្ឋានយុវជន |
| អគកឡ | អគ្គនាយកដ្ឋានកីឡា |
| អយក | អប់រំ យុវជន និងកីឡា |
| ឧស | នាយកដ្ឋានឧត្តមសិក្សា |

## ១.	សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ២០១៦-២០២០កន្លងមក ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ តាមរយៈការសម្រេចសមភាពយេនឌ័រក្នុងវិស័យអប់រំ ការបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជាស្ត្រីក្នុងការគ្រប់គ្រងវិស័យអប់រំ និងកសាងឥរិយាបថវិជ្ជមានរបស់សង្គម សំដៅឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍គោលដៅទី៣នោះគឺ "លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី" ចំណុចដៅទី១ "កាត់បន្ថយឱ្យបានច្រើននូវគម្លាតយេនឌ័រ ក្នុងការអប់រំកម្រិតមធ្យមសិក្សា" អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣និងទី៤ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្នុងការចូលរួមចំណែកលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី។ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ មុំទី៤នៃចតុកោណទី១ស្តីពី "ការអភិវឌ្ឍធនធានមនុស្ស" របស់រាជរដ្ឋាភិបាល គឺផ្តោតលើការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។

នៅក្នុងសេចក្តីសង្កេតសន្និដ្ឋាន ៥៧ ចំណុចលើរបាយការណ៍ជាតិលើកទី៦ស្តីពី ការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជាឆ្នាំ២០១៩ បានលើកឡើងអនុសាសន៍សម្រាប់វិស័យអប់រំដូចខាងក្រោម ៖

(ក)	បន្តអនុវត្តជំហាននានាដើម្បីបង្កើនភាពអាចរកបាន និងភាពទទួលបាននៃសាលាមធ្យមសិក្សាប្រកបដោយគុណភាពខ្ពស់ ជាពិសេស នៅតំបន់ជនបទ និងលុបបំបាត់នាំងឧបសគ្គជាក់លាក់ដែលក្មេងស្រីជួបប្រទះក្នុងការចូលរៀន និងស្ថិតនៅក្នុងសាលារៀននៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ដែលរួមមានភាពក្រីក្រ ឥរិយាបថមាតាបិតាអវិជ្ជមាន និងការនិយមចូលចិត្តចំពោះការអប់រំរបស់កូនប្រុស ពិការភាព ព្រមទាំងអាពាហ៍ពិពាហ៍ វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់។

(ខ)	ជំរុញ និងលើកទឹកចិត្តឱ្យក្មេងស្រី និងស្ត្រីចុះឈ្មោះចូលរៀនក្នុងការសិក្សាមិនមែនប្រពៃណីដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) តាមរយៈកម្មវិធីតម្រង់ទិស និងការផ្តល់ប្រឹក្សាអំពីអាជីពនៅក្នុងការអប់រំកម្រិតមធ្យម និងឧត្តមសិក្សា។

(គ)	ធានាថា គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលជាទៀងទាត់ និងគ្រប់ជ្រុងជ្រោយអំពីសមភាពយេនឌ័រ ដើម្បីលុបបំបាត់ភាពលំអៀងយេនឌ័រ ទស្សនៈយេនឌ័រតាមទម្លាប់ដែលមានការរើសអើង ជាពិសេស ក្នុងកម្មវិធីអប់រំបច្ចេកទេស បណ្តុះបណ្តាលវិជ្ជាជីវៈ និងបំណិនជីវិត និងដើម្បីជំរុញការបង្ហាញស្ត្រីជាជនគំរូ ដែលមានឧត្តមភាពក្នុងវិធីអាជីពមិនមែនប្រពៃណី។

ក្នុងការជំរុញការបញ្រ្ជាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យអប់រំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការសកម្មភាព និងវិធានការដាក់ស្តែងតាមរយៈផែនការ គម្រោង កម្មវិធីអប់រំ ការផ្តល់សេវាអប់រំ និងគ្រប់គ្រងដឹកនាំដោយផ្តោតលើការយកចិត្តទុកដាក់ជានាឱ្យកុមារា និងកុមារីបានទទួលលទ្ធភាពចូលរៀនដោយពេញលេញ និងស្មើភាពគ្នា។

## ២. លទ្ធផលសម្រេចបាន ក្នុងឆ្នាំ២០១៦-២០២០

សមិទ្ធផលសំខាន់ៗជាច្រើនសម្រេចបាន តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រក្នុងវិស័យអប់រំកន្លងមក ដូចខាងក្រោម ៖

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រក្នុងវិស័យអប់រំ ២០១៦-២០២០ ក្រសួងមានគោលបំណង "ធានាឱ្យកុមារ និងមនុស្សពេញវ័យ ទទួលបានសេវាអប់រំប្រកបដោយសមភាព សមធម៌ បរិយាបន្ន និងសម្រេចបានលទ្ធផលសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព" ដោយមានគោលដៅបីគឺ ១) ធានាសម្រេចឱ្យបានសមភាពយេនឌ័រក្នុងការចូលរៀន និងរៀនប្រកបដោយគុណភាពនៅគ្រប់សេវាអប់រំទាំងក្នុង ក្រៅប្រព័ន្ធ និងមិនផ្លូវការ ២) ធានាបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ និង៣)ធានាកសាងបរិស្ថាន អប់រំនិងឥរិយាបថវិជ្ជមានរបស់សង្គមដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។

សូចនាករ និងលទ្ធផលសំខាន់ៗ ត្រូវវាស់វែងពីវឌ្ឍនភាពនៃការសម្រេចបានគោលបំណង និងគោលដៅ មានដូចខាងក្រោម ៖

### ២.១ ការបណ្តុះឥរិយាបថសង្គមវិជ្ជមានចំពោះការអប់រំកុមារី និងសមតាពយេនឌ័រ ក្នុងចំណោមអ្នកពាក់ព័ន្ធនឹងវិស័យអប់រំ

#### ការអប់រំកុមារតូច

លទ្ធភាពទទួលសេវាអប់រំរបស់កុមារតូចមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយកុមារទទួលបានសេវាអប់រំមាន ៣៦៣ ៦៨១នាក់ ស្រី ៥០,០៨ ភាគរយ នៅឆ្នាំសិក្សា២០១៩-២០២០។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាព ១៩៣ ៨២៣នាក់ ស្មើ ៦២,៩ ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ ស្រី ៦៣,៦ ភាគរយ និងប្រុស ៦២,០ ភាគរយ។ សាលាមត្តេយ្យសិក្សាគ្រប់រូបភាពបានកើនពី ៦ ៩១៣ សាលា/កន្លែង នៅឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ៨ ០៦៧ សាលា/កន្លែង នៅឆ្នាំសិក្សា ២០១៩-២០២០ ដែលមានទីតាំង ១ ០៤២ ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៤៦ ឃុំ សង្កាត់។

ជារួម កុមារា កុមារីទទួលសេវាអប់រំកុមារតូចគ្រប់រូបភាព មានភាពប្រហាក់ប្រហែលគ្នា ក្នុងរយៈពេល ៥ឆ្នាំកន្លងមក ដោយសន្ទស្សន៍យុគភាពយេនឌ័រនៅបន្តស្មើនឹង ១,០។ លទ្ធផលទាំងនេះ សម្រេចបានតាមរយៈអន្តរាគមន៍មួយចំនួនដូចជា ការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន កម្មវិធីគាំទ្រផ្សេងៗ និងការចូលរួមជ្រោមជ្រែងយ៉ាងសកម្មពីសំណាក់មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ អាជ្ញាធរដែនដីជាដើម ដែលបានបង្កលក្ខណៈឱ្យសិស្សានុសិស្ស មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំ។

## ការអប់រំបឋមសិក្សា

បច្ចុប្បន្ន សាលាបឋមសិក្សាមានស្ទើរគ្រប់ទីតាំងភូមិសាស្ត្រ ដែលបានកើនពី ៧ ៤៤២ នៅឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ៧ ៨៥៦ នៅឆ្នាំសិក្សា២០១៩-២០២០ និងបានធ្វើឱ្យមានភាពប្រសើរឡើងដល់ការធ្វើដំណើរទៅសាលារៀន និងបន្តការសិក្សារបស់សិស្ស គួបផ្សំជាមួយការផ្តល់អាហារូបករណ៍និងផ្តល់អាហារនៅតាមសាលារៀន ការកើនឡើងនៃហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងកម្មវិធីលើកកម្ពស់សុខភាពសិក្សា ការអប់រំបរិយាបន្ន និងកម្មវិធីគាំទ្រផ្សេងៗទៀត។ ឆ្នាំសិក្សា២០១៩-២០២០ សាលាបឋមសិក្សាមានបង្គន់ ៩៩,៣ ភាគរយ ទឹកស្អាតសម្រាប់ទទួលទាន ៩០,៤ ភាគរយ កន្លែងលាងដៃ ៧៤,៧ ភាគរយ ជាពិសេសសាលាបឋមសិក្សាអនុវត្តស្តង់ដារអប្បបរមាទឹកស្អាតនិងអនាម័យ កម្រិត ១ មាន ៤០,៦ ភាគរយ។ បង្គន់អនាម័យ ត្រូវបានសាងសង់បន្ថែម និងបានដាក់ដាច់ដោយឡែកសម្រាប់សិស្សស្រី និងសិស្សប្រុស នៅតាមសាលារៀន ដើម្បីគាំទ្របរិស្ថានសិក្សាឱ្យសិស្សស្រីមករៀនកាន់តែទៀងទាត់ និងមានជំរាលសម្រាប់សិស្សមានពិការភាពផងដែរ។

ក្រសួងបាននិងកំពុងអនុវត្តគោលនយោបាយសាលាកុមារមេត្រីនៅតាមសាលាបឋមសិក្សា ដើម្បីកែលម្អបរិយាកាសនៃការរៀនសូត្រ និងធានានូវសុវត្ថិភាព សន្តិសុខសម្រាប់សិស្សស្របពេលដែលកំពុងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំសិស្សស្រីនៅក្នុងសហគមន៍។

ក្រសួងបាននិងកំពុងអនុវត្តការគ្រប់គ្រងតាមសាលារៀន ដោយមានការសហការពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល គណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស និងសហគមន៍ ក្នុងការបង្កើនការចូលរៀននៅបឋមសិក្សា ក៏ដូចជាការកែលម្អគុណភាពអប់រំផងដែរ។

រាជរដ្ឋាភិបាលមានគោលនយោបាយផ្តល់អាហារូបករណ៍ដល់សិស្សពូកែ និងសិស្សក្រីក្រ ក្នុងនោះយ៉ាងហោចណាស់ត្រូវមានសិស្សស្រី ៦០ ភាគរយ។ អាហារូបករណ៍សម្រាប់សិស្សក្រីក្រដែលបានប្រើប្រាស់ថវិកាជាតិ បានគ្របដណ្តប់លើសាលាបឋមសិក្សា ៤ ៩៥១ មានសិស្ស ១១០ ១៥៦នាក់ ស្រី ៥៤ ភាគរយ។ សិស្សស្រីទទួលអាហារូបករណ៍ជាស្បៀងពីកម្មវិធីអង្គការស្បៀងអាហារពិភពលោក ៥៦ ភាគរយ។

ការចូលរៀននៅបឋមសិក្សា ក្នុងរយៈពេល ៥ឆ្នាំកន្លងមក សម្រេចបានអត្រាពិតនៃការសិក្សាក្នុងរង្វង់ ៩៨ ភាគរយ និងអត្រាបញ្ចប់ការសិក្សា ក្នុងរង្វង់ ៨០ ភាគរយ។ ឆ្នាំសិក្សា២០១៩-២០២០ សិស្សបឋមសិក្សាសរុប ២ ១៦៣ ១៤៣នាក់ ស្រី១ ០៣៩ ៩៣៦នាក់ (៤៨,១ ភាគរយ)។ សិស្សស្រីនៅសាលារដ្ឋមាន ៤៧,៩ ភាគរយ និងសាលាឯកជន ៤៩,៤ ភាគរយ។ សិស្សស្រីជនជាតិដើមភាគតិចក្នុងកម្មវិធីអប់រំពហុភាសាមាន ៤៨,៨ ភាគរយ និងសិស្សស្រីមានពិការភាព ៤០,៥ ភាគរយ។ អត្រាឡើងថ្នាក់នៅបឋមសិក្សាសម្រាប់សិស្សស្រីមាន ៨៩,៤ ភាគរយ និងសិស្សប្រុស ៨៤,៥ ភាគរយ អត្រាត្រួតថ្នាក់ (ស្រី៤,៧ ភាយរយ និងប្រុស ៧,៨ ភាគរយ) អត្រាបោះបង់ការសិក្សា (ស្រី ៥,៩ ភាគរយ និងប្រុស៧,៧ ភាគរយ) និងអត្រាបញ្ចប់ការសិក្សា (ស្រី ៩២,៧ ភាគរយ និងប្រុស ៨៤,១ ភាគរយ)។

ជារួម ការចូលរៀននៅបឋមសិក្សារបស់កុមារា និងកុមារី គឺមានសមភាពយេនឌ័រ ដោយមានសន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួម និងអត្រាពិតនៃការសិក្សា ស្ថិតនៅក្នុងរង្វង់ ១,០។

## ការអប់រំមធ្យមសិក្សា

នៅឆ្នាំសិក្សា២០១៩-២០២០ សិស្សមធ្យមសិក្សាបឋមភូមិសរុប ៦៥៥ ០៥៥ នាក់ ស្រី ៥២,៥ ភាគរយ (សិស្សស្រីនៅមធ្យមសិក្សាបឋមភូមិរដ្ឋ ៥២,៦ ភាគរយ និងឯកជន ៥១,៤ ភាគរយ)។ ការចូលរៀនរបស់សិស្សស្រីនៅមធ្យមសិក្សាបឋមភូមិ កាន់តែមានភាពប្រសើរជាងសិស្សប្រុស ក្នុងរយៈពេល ៥ឆ្នាំកន្លងមក ដោយគម្លាតសន្ទស្សន៍យុគភាពនៃអត្រារួមនៃការសិក្សាកាន់តែធំ (កើនពី ១,១ ដល់ ១,១៨)។ គម្លាតនៃអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិរវាងសិស្សស្រី និងសិស្សប្រុសក៏កាន់តែធំផងដែរ ដោយសន្ទស្សន៍យុគភាពកើនពី ១,១ នៅឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ១,២៤ ឆ្នាំសិក្សា ២០១៩-២០២០។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ គឺ ៤២,៤ ភាគរយសម្រាប់សិស្សប្រុស និង ៥២,៥ ភាគរយ សម្រាប់សិស្សស្រី ដែលមានន័យថា អត្រាបញ្ចប់ការសិក្សារបស់សិស្សស្រី ប្រមាណ ២៤ ភាគរយ ខ្ពស់ជាងអត្រារបស់សិស្សប្រុស។

មធ្យមសិក្សាទុតិយភូមិសិស្សសរុបមាន ៣៥៨ ៥៥៣នាក់ ស្រី ៥៤,៥ ភាគរយ (សិស្សស្រីនៅមធ្យមសិក្សាទុតិយភូមិរដ្ឋ ៥៤,៨ ភាគរយ និងឯកជន ៥១,២ ភាគរយ)។ គម្លាតសន្ទស្សន៍យុគភាពនៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិនៅតែធំ គឺ១,៣ នៅឆ្នាំសិក្សា ២០១៩-២០២០។ ឆ្នាំ២០១៩ ចំនួនបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានកើនដល់ ៧៩ ០៥២នាក់ (៦៨,៦២ ភាគរយ) ស្រី ៤៣ ៧២៨នាក់ (៧៣,២១ ភាគរយ ខ្ពស់ជាងបន្តិចមធ្យមភាគ ថ្នាក់ជាតិ)។ បេក្ខជនប្រឡងជាប់និទ្ទេស A សរុប ៤៤៣ នាក់ ស្រី ២២៣ នាក់ (៥០,៣ ភាគរយ) និទ្ទេស B សរុប ២ ៤៣០ នាក់ ស្រី ១ ៣០៦ នាក់ (៥៣,៧ ភាគរយ) និងនិទ្ទេស C សរុប ៥ ៨៤៧ នាក់ ស្រី ៣ ៤១៤ នាក់ (៥៨,៤ ភាគរយ)។

សិស្សអប់រំបច្ចេកទេសកើនពី ៨៦៨ នាក់ ស្រី ៣២៦នាក់ នៅឆ្នាំសិក្សា២០១៥-២០១៦ ដល់ ២ ៧១៧នាក់ ស្រី ១ ០៤២នាក់ ឆ្នាំសិក្សា២០១៩-២០២០ ដែលបានបង្ហាញថា សិស្សស្រីចូលរៀនអប់រំបច្ចេកទេសមិនសូវមានភាពប្រែប្រួល ដោយមានក្នុងរង្វង់ជាង ៣៨ ភាគរយ។

ក្រសួងបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ (៧២ ៤១៨នាក់) និងមធ្យមសិក្សាទុតិយភូមិ (១០ ៩៦៧នាក់) ក្នុងនោះ សិស្សស្រី ៦០ ភាគរយ។ ក្រៅពីនេះ ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ក៏បានផ្តល់អាហារូបករណ៍មួយចំនួនតូច ដែលមានសិស្សស្រីប្រមាណ ៥០ ភាគរយ។

ក្រសួងមានគោលបំណងឱ្យមានអនុវិទ្យាល័យនៅតាមឃុំ-សង្កាត់ និងវិទ្យាល័យនៅតាមគ្រប់ក្រុងស្រុក ខណ្ឌទាំងអស់។ បច្ចុប្បន្ន គ្រឹះស្ថានមធ្យមសិក្សាមាន ២ ០៤៩ (អនុវិទ្យាល័យ ១ ៣៣៤ និងវិទ្យាល័យ ៧១៥) កើន ១៨៤ (អនុវិទ្យាល័យ ៤០ និងវិទ្យាល័យ ១៤៤) បើធៀបនឹងឆ្នាំសិក្សា២០១៥-

២០១៦។ ឃុំ សង្កាត់ ១១៥ លើ ១ ៦៤៦ មិនទាន់មានអនុវិទ្យាល័យ ក្នុងនោះ រាជធានីភ្នំពេញ ៤៦សង្កាត់ មិនតម្រូវឱ្យបង្កើតអនុវិទ្យាល័យ និងខេត្តរតនគិរី ២៧ឃុំ មិនទាន់ទាមទារឱ្យបង្កើតអនុវិទ្យាល័យ ដោយឡែក ស្រុក ២ លើ ២០៣ ស្មើ ០,៩៨ ភាគរយ មិនទាន់មានវិទ្យាល័យ គឺ បុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងក្រុងកោះរ៉ុង ខេត្តព្រះសីហនុ។

ក្រសួងអប់រំ យុវជន និងកីឡា ធ្វើបច្ចុប្បន្នកម្ម និងជំរុញការអនុវត្តផែនការគោលសម្រាប់ការអប់រំ បច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ សំដៅបង្កើនការតម្រង់ទិសការសិក្សាទៅអាជីព និងពង្រីកការអប់រំ បច្ចេកទេសឱ្យមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស តាមទស្សនាទាន "ខេត្តមួយមានវិទ្យាល័យ ចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលមធ្យម និងស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលវែង"។ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបានកើនពី ៣ នៅឆ្នាំសិក្សា២០១៤-២០១៥ ដល់ ១៦ ឆ្នាំសិក្សា២០១៩-២០២០ ដោយមានមុខជំនាញអគ្គិសនី អេឡិចត្រូនិក បសុវប្បកម្ម ក្សេត្រសាស្ត្រ មេកានិច និងកែច្នៃចំណីអាហារ។ កម្មវិធីអប់រំបំណិនជីវិតត្រូវ បានកែលម្អឱ្យកាន់តែប្រសើរឡើង និងបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពដើម្បី ផ្តល់សេវាមគ្គុទេសអាជីព និងការផ្តល់ប្រឹក្សានៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ។

ជាសរុបមក សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួមនៃការសិក្សានៅបឋមសិក្សា ០,៩៩ និងនៅ មធ្យមសិក្សាបឋមភូមិ ១,១៨ ខណៈដែលសន្ទស្សន៍យុគភាពយេនឌ័រនៅមធ្យមសិក្សាទុតិយភូមិ គឺ ១,៣។ ចំណុចនេះ បង្ហាញពីការបន្តការសិក្សារបស់សិស្សស្រីខ្ពស់ជាងសិស្សប្រុសនៅមធ្យមសិក្សាទុតិយភូមិ។

***រូបទី១ ៖ សន្ទស្សន៍យុគភាពយេនឌ័រ អត្រារួមនៃការសិក្សា***



## ការអប់រំឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១២៤ កើន ៦ ធៀបនឹងឆ្នាំ២០១៦ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៤៨ (កើន ២) និងឯកជន ៧៦ ដែលមានទីតាំងស្ថិតនៅ ២០ ខេត្ត និងរាជធានី។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៦។

និស្សិតកំពុងសិក្សានៅឧត្តមសិក្សាទាំងអស់មាន ២២២ ៨៧៩នាក់ ស្រី ១០៦ ៩៥២នាក់ ស្មើ ៤៨ ភាគរយ។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង ១៩ ៥៧៥ នាក់ ស្រី ៥២,៥ ភាគរយ ក្នុងនោះ និស្សិតអាហារូបករណ៍ ២ ៣៧៤ នាក់ ស្រី ៥៥,៧ ភាគរយ។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រមាន ១៧៩ ២៥៨ នាក់ ស្រី ៥០,៧ ភាគរយ ក្នុងនោះ និស្សិតអាហារូបករណ៍មាន ២៧ ៣៣៨នាក់ ស្រី ៥១,៨ភាគរយ។ និស្សិតបរិញ្ញាបត្រកំពុងសិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម)មាន ២៨,៣ ភាគរយ (ប្រុស ៤០,១ ភាគរយ ស្រី ១៦,៩ ភាគរយ)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មាន ២៣ ២៥៦ នាក់ ស្រី ២៤,៤ភាគរយ និងថ្នាក់បណ្ឌិត ៧៩០នាក់ ស្រី ៧,៣ភាគរយ។ អត្រារួមនៃការសិក្សានៅឧត្តមសិក្សា គឺ ១២,0 ភាគរយ (ប្រុស ១២,២ ភាគរយ ស្រី ១១,៨ ភាគរយ)នៅឆ្នាំសិក្សា ២០១៩-២០២០។

បច្ចុប្បន្ន អន្តេវាសិកដ្ឋានសរុបមាន ២៣ អគារ ដែលមាននិស្សិតនារីស្នាក់នៅចំនួន ១ ៤៨០នាក់ ក្នុងនោះ អន្តេវាសិកដ្ឋាន ៧ ជារបស់គ្រឹះស្ថានឧត្តមសិក្សាឯកជនដែលមាននិស្សិតនារី២៧៥នាក់។ និស្សិតកម្ពុជា និងបរទេសស្នាក់នៅក្នុងមជ្ឈមណ្ឌលអន្តេវាសិកដ្ឋាន ៨០២នាក់ ស្រី ៦០៦នាក់ ស្មើ ៧៥,៥៦ ភាគរយ។

ក្រសួងអប់រំ យុវជន និងកីឡាបានជំរុញនិងបង្កើនចំនួននិស្សិតចូលសិក្សាផ្នែកស្ទែមនៅឧត្តមសិក្សា តាមរយៈការលើកទឹកចិត្ត និងគាំទ្រការបង្កើតកម្មវិធីបណ្តុះបណ្តាលថ្មី និងគ្រឹះស្ថានឧត្តមសិក្សាថ្មី ដែលផ្តោតលើផ្នែកស្ទែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងកាត់បន្ថយគម្លាតជំនាញ។

ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតជាចម្បងលើការលើកកម្ពស់គុណភាពអប់រំនៅគ្រប់ភូមិសិក្សា និងការធានាសមធម៌ បរិយាបន្នក្នុងការចូលរៀនរបស់អ្នកសិក្សា ជាពិសេសនារីភេទ តាមរយៈមធ្យោបាយនានាដូចជា ការផ្តល់អាហារូបករណ៍ដែលផ្តោតលើអាទិភាពសិស្សទូទៅ សិស្សពូកែ សិស្សនារី សិស្សក្រីក្រ សិស្សមកពីតំបន់ជាច់ស្រយាល និងសិស្សមានពិការភាព ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតនារី និងការរៀបចំឱ្យមានគ្រឹះស្ថានឧត្តមសិក្សានៅតាមខេត្ត។ ជាងនេះទៀត ក្រសួងបានផ្តល់ឱកាស និងលើកទឹកចិត្តឱ្យសិស្ស-និស្សិតនារីក្នុងការបន្តការសិក្សារហូតដល់ឧត្តមសិក្សា តាមរយៈការលើកកម្ពស់ស្ត្រីក្នុងសង្គម ការអប់រំពីសីលធម៌និងយេនឌ័រ ការអប់រំពីសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងគ្រួសារ និងសង្គមក្នុងកម្មវិធីថ្នាក់ឆ្នាំមូលដ្ឋាន។

## ការអប់រំក្រៅប្រព័ន្ធ

អត្រាអក្ខរភាពមនុស្សពេញវ័យអាយុ១៥ឆ្នាំឡើង បានកើនពី ៨០,៥ ភាគរយ (ស្រី ៧៥ ភាគរយ) ដល់ ៨៧,៧ ភាគរយ (ស្ត្រី ៨៤,៨ ភាគរយ) នៅឆ្នាំ២០១៩។ អត្រាអក្ខរកម្មនៅតំបន់ជនបទ គឺ ៨៣,៨ ភាគរយ និងនៅទីប្រជុំជន ៩៣,៣ ភាគរយ។ អត្រាអក្ខរភាពបុរស និងស្ត្រីខុសគ្នាច្រើនតាមក្រុមអាយុ និងទីតាំងភូមិសាស្ត្រ ប៉ុន្តែអត្រារបស់ស្ត្រីខ្ពស់ជាងបុរសបន្តិចបន្តួចចំពោះក្រុមអាយុ ១៥-១៩ ឆ្នាំ ហើយអត្រារបស់ស្ត្រីទាបជាងខ្លាំងធៀបនឹងអត្រារបស់បុរស អាយុ ៦០ ឆ្នាំឡើង។ អ្នកសិក្សាក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ១៩ ១០១នាក់ ស្រី ៦៥,៤ ភាគរយ។ អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមាន ៦ ៧៦០នាក់ ស្រី ៤៥,៩ ភាគរយ និងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ មានអ្នកសិក្សា ៣៧៤នាក់ ស្រី ៤២,៥ ភាគរយ។

## ការអភិវឌ្ឍយុវជន

ក្រសួងបានបូកសរុបចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" នៅថ្នាក់ជាតិ មានអ្នកចូលរួម ៤០១នាក់ ស្រី ៥១ភាគរយ និងមន្ត្រីដឹកនាំ ២៥នាក់ ស្រី ២០ភាគរយ ដើម្បីអភិវឌ្ឍបំណិនយុវជន និងកុមារលើចលនាប្រឡងប្រណាំង ៣ល្អ កូនល្អ សិស្សល្អ និងមិត្តល្អ ដើម្បីក្លាយជាពលរដ្ឋល្អ។

ក្រុមប្រឹក្សាកុមារកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាបឋមភូមិ គិតពីថ្នាក់ទី៤ ដល់ថ្នាក់ទី៩។ ក្រុមប្រឹក្សាកុមារកម្ពុជាមាន ៨ ៩៦៧ ដែលមានសមាជិក ១ ៥៥២ ៨៤០នាក់ ស្រី ៧៨៨ ៩០១នាក់ (៥០,៨ភាគរយ)។ ក្រុមប្រឹក្សាយុវជនកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តនៅមធ្យមសិក្សាទុតិយភូមិ។ ក្រុមប្រឹក្សាយុវជនកម្ពុជា មាន ៥២៥ ដែលមានសមាជិក ៣២១ ១៤៥នាក់ ស្រី ១៧១ ៤៩៤នាក់ (៥៣,៤ភាគរយ)។ ក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា មានសាខា អនុសាខា និងសមាជិកជាកុមារ យុវជនកើនឡើង ដោយមានកម្មវិធីស្ម័គ្រចិត្ត កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន កំណើនគ្រឹះស្ថានសិក្សា និងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ ជាពិសេស ជួយដល់ការងារស្វ័យគ្រប់គ្រងសាលារៀន គាំទ្រសកម្មភាពក្លឹប ការងារស្ម័គ្រចិត្ត និងជួយសិស្សប្រឡងថ្នាក់ទី១២។

ក្រសួងបានពង្រីកគម្រោងសាកល្បងកម្មវិធីអប់រំសហគ្រិនភាព "ការយល់ដឹងពីធុរកិច្ច" ដល់សិស្សថ្នាក់ទី១០ និងទី១១ ចំនួន ២៥ថ្នាក់ (១ថ្នាក់/រាជធានី ខេត្ត) មានសិស្សចុះឈ្មោះចូលរៀន ៦២៥នាក់ ស្រី ៥២ភាគរយ។

ក្រសួងបានរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឈ្មោះថា "កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត" ដើម្បីផ្តល់ឱកាសដល់យុវជនដែលបោះបង់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ទទួលបានឱកាសបន្តការសិក្សា និងបណ្តុះបណ្តាលជំនាញដែលឆ្លើយតបទៅគោលនយោបាយសិក្សាពេញមួយជីវិតរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយូណេស្កូ។ បច្ចុប្បន្នមានសិស្សចុះឈ្មោះចូលរៀន ៣១៣នាក់ ស្រី ៤២ភាគរយ។

ក្រសួងបានផ្សព្វផ្សាយអប់រំស្តីពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការបង្ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ និងសុវត្ថិភាពចរាចរផ្លូវគោក ដល់យុវជនកាកបាទក្រហម

យុវជនកាយរឹទ្ធិ និងក្រុមប្រឹក្សាយុវជនកម្ពុជា ១ ៣០០នាក់ ស្រី ៦០ភាគរយ នៅតាមគ្រឹះស្ថានមធ្យមសិក្សា ក្នុង ១០ ខេត្ត។

### ការអប់រំកាយ និងកីឡា

ក្រសួងបានរៀបចំការប្រកួតកីឡាថ្នាក់ជាតិ៖ សិស្សបឋមសិក្សាមានប្រតិភូកីឡានិងកីឡាករ ១ ៥៣០នាក់ ស្រី ៦៨៤នាក់ លើ ៤ប្រភេទកីឡា និងសិស្សមធ្យមសិក្សា មានប្រតិភូកីឡានិងកីឡាករ ៣ ៤៥៩នាក់ ស្រី ១ ២៩០នាក់ លើ ១១ប្រភេទកីឡា។

ក្នុងការលើកកម្ពស់សមត្ថភាពគ្រូបង្វឹក និងកីឡាករ ៖ ក្រសួងបានទទួលគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនីថ្នាល ៥០០នាក់ ស្រី ១២០នាក់ មកហ្វឹកហាត់លើ ៣១ ប្រភេទកីឡា ដើម្បីត្រៀមលក្ខណៈឆ្ពោះទៅស៊ីហ្គេមឆ្នាំ២០២៣ និងទទួលគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនី ៥០៤នាក់ ស្រី ១១៧នាក់ មកហ្វឹកហាត់លើ ៣៤ ប្រភេទកីឡាសម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣០និងការប្រកួតជាលក្ខណៈអន្តរជាតិនានា ព្រមទាំងទទួលគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនី ជនពិការ ៥២នាក់ ស្រី១២នាក់ មកហ្វឹកហាត់លើ ៦ប្រភេទកីឡា សម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីប៉ាហ្គេម និងការប្រកួតជាលក្ខណៈអន្តរជាតិនានា។

ការចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣០ នៅហ្វីលីពីន ទទួលបានមេដាយមាស ៤គ្រឿង ប្រាក់ ៦គ្រឿង និងសំរឹទ្ធិ ៣៦គ្រឿង។ ការប្រកួតកីឡាប៉េតង់ជ្រើសរើសជើងឯកពិភពលោកយុវជននិងស្ត្រី កីឡាការិនី កែ ឡេង ទទួលបានមេដាយមាសចំនួន ៤ដងជាប់ៗគ្នាមុនគេលើពិភពលោក។

*តារាងទី១ ៖ លទ្ធផលនៃការប្រកួតកីឡាលក្ខណៈអន្តរជាតិ*

| ប្រភេទកីឡា | ប្រតិភូ | កីឡាករ | កីឡាការិនី | មេដាយ | | | សរុប |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | |
| ការប្រកួតជើងឯកពិភពលោក | ៥០ | ៧៨ | ៣៩ | ១៤ | ១៣ | ១៥ | ៤២ |
| ការប្រកួតជើងឯកអាស៊ី | ៣៩ | ៥២ | ៣៩ | ១២ | ០៨ | ១២ | ៣២ |
| ការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ | ១១ | ២០ | ១៦ | ០០ | ០០ | ០៧ | ០៧ |
| ការប្រកួតកីឡាបើកទូលាយ | ៣៥ | ៧៩ | ៣១ | ០៩ | ០២ | ០៥ | ១៦ |
| ការប្រកួតកីឡាជនពិការ | ០៩ | ៣៤ | ០២ | ០០ | ០១ | ០២ | ០៣ |
| ការប្រកួតកីឡាស៊ីហ្គេមលើកទី៣០ | ១២៣ | ២០៦ | ៧០ | ០៤ | ០៦ | ៣៦ | ៤៦ |
| សរុប | | | | ៣៩ | ៣០ | ៧៧ | ១៤៦ |

## អន្តរាគមន៍ចម្បងៗសម្រាប់លើកកម្ពស់យេនឌ័រក្នុងវិស័យអប់រំ

សមិទ្ធផលទាំងនេះសម្រេចបាន តាមរយៈការដាក់ចេញយុទ្ធសាស្ត្រ និងអន្តរាគមន៍ដោយផ្ទាល់ និងជាប្រយោល ក្នុងគោលបំណងលើកកម្ពស់កុមារីនិងស្ត្រីនៅក្នុងអនុវិស័យសំខាន់ៗ និងអន្តរអនុវិស័យ ដូចខាងក្រោម ៖

- ការសាងសង់សាលារៀននៅកាន់តែជិតផ្ទះប្រជាជន ដើម្បីបង្កលក្ខណៈឱ្យសិស្សមកពីគ្រួសារក្រីក្រ បានចូលរៀន ជាពិសេសកុមារី ដើម្បីកាត់បន្ថយចំណាយ និងសុវត្ថិភាពនៃការធ្វើដំណើរ
- ការសាងសង់បន្ទប់ទឹក និងបង្គន់អនាម័យដាច់ដោយឡែកសម្រាប់ សិស្សស្រី សិស្សប្រុស និងសិស្ស មានពិការភាព ជាពិសេស នៅកម្រិតមធ្យមសិក្សា ដើម្បីជំរុញដល់ការមកសិក្សាឱ្យបានទៀងទាត់
- ការសាងសង់ជម្រាលសម្រាប់សិស្សមានពិការភាព
- ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្ស-និស្សិត គរុសិស្ស ជានារីស្នាក់នៅដូចជា នៅតាមសាលា គរុកោសល្យ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងសាកលវិទ្យាល័យ
- ការអនុវត្តកម្មវិធីសាលាកុមារមេត្រី និងការបង្កើតកម្មវិធីទីប្រឹក្សាកុមារីនៅតាមសាលារៀន
- ការលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការអប់រំស្ត្រី ដែលការវិនិយោគតាំងពីម្តាយរហូត ដល់កូន ព្រមទាំងយកចិត្តទុកដាក់លើផ្នត់គំនិតរបស់សង្គមចំពោះកូនស្រី
- ការផ្តល់អាហារូបករណ៍សម្រាប់សិស្សអាទិភាពទូទៅ សិស្សពូកែ អាទិភាពនារី អាទិភាពក្រីក្រ អាទិភាព តំបន់ដាច់ស្រយាល និងសិស្សមានពិការភាព ជាពិសេសសិស្សនារីឱ្យបានយ៉ាងតិច ៦០% នៃចំនួនសិស្សទទួលអាហារូបករណ៍បានចូលរៀននៅឧត្តមសិក្សា
- ការផ្តល់ និងពង្រាយគ្រូឱ្យបានគ្រប់គ្រាន់ ជាពិសេសគ្រូជាស្ត្រី សម្រាប់ការបង្រៀនសិស្សនៅថ្នាក់ កម្រិតទាប (មត្តេយ្យសិក្សា និងបឋមសិក្សា)
- ការអភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សាគោល សម្ភារសិក្សា ការកែលម្អសកម្មភាពបង្រៀន និងរៀន ឱ្យមានការទាក់ទាញ ជាពិសេសការលើកកម្ពស់ស្ត្រី កុមារីដោយគ្មានការរើសអើងចំពោះភេទ
- ការរៀបចំកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសលើមុខជំនាញ គណនេយ្យ ទេសចរណ៍ និងកែច្នៃអាហារ ដើម្បីទាក់ទាញសិស្សស្រីចូលរៀន
- ការពង្រីកការអប់រំបច្ចេកទេស និងអប់រំបំណិនជីវិតនៅមធ្យមសិក្សា ក្នុងគោលបំណងផ្តល់ជំនាញ ដែលចាំបាច់សម្រាប់ជីវិតប្រចាំថ្ងៃដែលមានប្រយោជន៍ ជាពិសេសដល់សិស្សស្រី ទាំងពេលកំពុង សិក្សា និងទាំងក្នុងករណីមិនអាចបន្តការសិក្សាទៅថ្នាក់ខ្ពស់បាន

- ការបញ្ចូលកម្មវិធីបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូគ្រប់កម្រិត និងការបំប៉នគ្រូឧទ្ទេស គ្រូបង្រៀន និងអ្នកគ្រប់គ្រងស្តីពីចំណេះដឹងយេនឌ័រ ការបញ្ជ្រាបយេនឌ័រក្នុងការបង្រៀន និងរៀន និងការងារគ្រប់គ្រងអប់រំ
- ការបំប៉នស្តីពី ភាពឆាប់ចាប់អារម្មណ៍លើយេនឌ័រក្នុងការងារអប់រំជូនគ្រូឧទ្ទេស និងនាយក នាយករង នៅតាមសាលាគរុកោសល្យ (វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម និងសាលាគរុកោសល្យ និងវិក្រឹតការ)
- ការបំប៉នស្តីពីការគ្រប់គ្រងសាលារៀនជូននាយកសាលាបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តោតលើខ្លឹមសារស្តីពី យេនឌ័រនិងការអភិវឌ្ឍសាលារៀន យេនឌ័រនិងអំពើជួញដូរមនុស្ស យេនឌ័រនិងអំពើហិង្សាក្នុងគ្រួសារ យេនឌ័រនិងសុខភាព យេនឌ័រនិងការប្រែប្រួលអាកាសធាតុ
- ការបំប៉នស្តីពីការបង្កើត ការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធីទីប្រឹក្សាកុមារី ជូននាយកនាយករងសាលា ទីប្រឹក្សាកុមារី គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យ
- ការផ្តល់ការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺឆ្លងផ្សេងៗទៀត
- ការផ្តល់អាទិភាពដល់កុមារី ស្ត្រី ក្នុងការប្រកួតប្រជែង និងការជ្រើសរើសនានា។

## ២.២ ការបង្កើនសមភាពយេនឌ័រនៅក្នុងការអប់រំ និងការផ្ដល់ភាពអង់អាចក្លាហានដល់ស្ត្រីក្នុងការងារគ្រប់គ្រង

ក្រសួងបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ២០១៦-២០២០ ដោយសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើនសមភាពយេនឌ័រនៅក្នុងវិស័យអប់រំគ្រប់កម្រិត និងផ្ដល់ភាពអង់អាចដល់ស្ត្រីក្នុងការងារភាពជាអ្នកដឹកនាំ និងគ្រប់គ្រង។ សមិទ្ធផលសម្រេចបានដូចមាននៅក្នុងតារាងខាងក្រោម។

*តារាងទី២ ៖ វឌ្ឍនភាពសម្រេចបាន ការបង្កើនសមភាពយេនឌ័រ និងការផ្ដល់ភាពអង់អាចក្លាហានដល់ស្ត្រី*

| សូចនាករ | ឯកតា | ឆ្នាំមូលដ្ឋាន | ជាក់ស្ដែង | | | | | ចំណុចដៅ | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២០ | |
| **ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រងនៅថ្នាក់កណ្ដាល** | | | | | | | | | |
| - អគ្គនាយក សាកលវិទ្យាធិការ | % | 7.1 | 7.1 | 6.7 | 6.7 | 12.5 | 12.5 | 10.0 | ↑ |
| - អគ្គនាយករង សាកលវិទ្យាធិការរង | % | 9.3 | 6.0 | 7.5 | 9.3 | 5.8 | 6.0 | 10.0 | ↓ |
| - ប្រធាននាយកដ្ឋាន | % | 9.7 | 3.0 | 3.1 | 2.9 | 5.6 | 11.1 | 10.0 | ↑ |
| - អនុប្រធាននាយកដ្ឋាន | % | 15.1 | 14.0 | 15.6 | 19.8 | 18.3 | 18.2 | 20.0 | → |
| - ប្រធានការិយាល័យ | % | 20.7 | 24.7 | 24.1 | 20.4 | 20.6 | 19.6 | 20.0 | → |
| - អនុប្រធានការិយាល័យ | % | 24.5 | 20.6 | 21.9 | 23.6 | 23.7 | 24.9 | 25.0 | → |
| **ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត** | | | | | | | | | |
| - ប្រធានមន្ទីរ | % | 8.0 | 8.0 | 0.0 | 0.0 | 4.0 | 4.0 | 10.0 | ↓ |
| - អនុប្រធានមន្ទីរ | % | 11.4 | 14.7 | 17.6 | 22.4 | 22.7 | 23.5 | 15.0 | ↑ |
| - ប្រធានការិយាល័យ | % | 14.2 | 14.2 | 14.6 | 13.2 | 13.7 | 12.9 | 15.0 | → |
| - អនុប្រធានការិយាល័យ | % | 22.1 | 23.3 | 23.6 | 22.6 | 22.6 | 23.4 | 25.0 | → |
| **ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ** | | | | | | | | | |
| - ប្រធានការិយាល័យ | % | 5.6 | 6.0 | 5.2 | 4.7 | 5.6 | 5.4 | 10.0 | ↓ |
| - អនុប្រធានការិយាល័យ | % | 11.0 | 12.3 | 12.6 | 13.1 | 12.5 | 14.1 | 15.0 | → |
| **ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងនៅថ្នាក់សាលារៀន** | | | | | | | | | |
| - នាយិកា | % | 11.3 | 12.1 | 12.5 | 12.7 | 12.9 | 13.5 | 15.0 | → |
| - នាយិការង | % | 19.3 | 20.3 | 20.8 | 20.8 | 21.2 | 21.5 | 25.0 | → |
| **ភាគរយគ្រូបង្រៀនជាស្ត្រី** | | | | | | | | | |
| - ទូទាំងប្រទេស | % | 49.1 | 43.5 | 44.5 | 45.5 | 45.7 | 46.2 | 50.0 | → |
| - ទីប្រជុំជន | % | 56.4 | 47.9 | 47.9 | 47.4 | 47.4 | 51.7 | 60.0 | → |
| - ជនបទ | % | 46.5 | 44.8 | 44.0 | 45.1 | 45.6 | 44.9 | 50.0 | → |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## ស្ថានភាពចំនួនស្ត្រីជាមន្ត្រីរាជការជានារី

ក្នុងឆ្នាំ២០២០ បុគ្គលិកអប់រំគ្រប់ប្រភេទក្របខណ្ឌចំនួន ១២១ ៦៨០នាក់ ស្រី ៥៦ ១៦៣ នាក់ (៤៦,១៥ ភាគរយ) ថ្នាក់ជាតិចំនួន ៣ ៧៥៨ នាក់ ស្រី ៩៩៩ នាក់ (២៦,៥៨ ភាគរយ) និងថ្នាក់ក្រោមជាតិចំនួន ១១៧ ៩២២ នាក់ ស្រី ៥៥ ១៦៤ នាក់ (៤៦,៧៨ ភាគរយ)។

គ្រូមត្តេយ្យសិក្សា ៣ ៧២១នាក់ ស្រី ៣ ៦១៧ នាក់ (៩៧,២០ ភាគរយ) គ្រូបឋមសិក្សា ៥៤ ៨៧០ នាក់ ស្រី ២៨ ៥០៦ នាក់ (៥១,៩៥ ភាគរយ) គ្រូបង្រៀនកម្រិតមូលដ្ឋាន ៤២ ៣៤៣នាក់ ស្រី ១៨ ០៧១ នាក់ (៤២,៦៧ ភាគរយ) គ្រូបង្រៀន កម្រិតមូលដ្ឋាន (អប់រំកាយ និងកីឡា) ២ ៣៥៧នាក់ ស្រី ៤៩៥ នាក់ (ស្រី ២១ ភាគរយ) គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅវិទ្យាល័យ) ១៦ ៥៨១ នាក់ ស្រី ៥ ១០៥ នាក់ (៣០,៩០ ភាគរយ) គ្រូបង្រៀន កម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ១ ៦៣៦ នាក់ ស្រី ៣៤៣នាក់ (ស្មើ ២០,៩៦ភាគរយ) អធិការបឋម ៤៧នាក់ ស្រី ៦នាក់ (ស្មើ ១២,៧៦ភាគរយ) អធិការមធ្យម ១២៥នាក់ ស្រី ២០នាក់ (ស្មើ ១៦ភាគរយ)។

ក្រសួងកំពុងបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតនៅតាមសាលាគរុកោសល្យនានាចំនួន ៥ ៩៤៤ នាក់ ស្រី ៣ ៨៤៥នាក់ (៦៤,៦៨ ភាគរយ) ក្នុងនោះគ្រូមត្តេយ្យសិក្សា ៤០០នាក់ ស្រី ៣៨៦នាក់ (៩៦,៥ ភាគរយ) គ្រូបឋមសិក្សា ៣ ២៥៥នាក់ ស្រី ២ ២៤៣ នាក់ (៦៨,៩០ ភាគរយ) គ្រូបង្រៀនកម្រិតមូលដ្ឋាន ១ ២៧៤ នាក់ ស្រី ៧៣០ នាក់ (៥៧,២៩ ភាគរយ) និងគ្រូបង្រៀនកម្រិតឧត្តម ១ ០១៥ នាក់ ស្រី ៤៨០នាក់ (៤៧,២៩ ភាគរយ)។

ក្រសួងបានបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យទទួលបានសញ្ញាបត្របរិញ្ញាបត្រ ជំនាន់ទី៣ ចំនួន ៥៦៩ នាក់ ស្រី ២៥៤ នាក់ (៤៤,៦៣ ភាគរយ)។

សាលាគរុកោសល្យទាំងអស់ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្ត សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម) សុទ្ធតែមានអន្តេវាសិកដ្ឋានសម្រាប់គរុសិស្ស គរុនិស្សិត។

## ភាគរយស្ត្រីដែលបានតែងតាំងក្នុងរចនាសម្ព័ន្ធ ការធ្វើសេចក្តីសម្រេចចិត្ត

អ្នកគ្រប់គ្រងនៅថ្នាក់ជាតិ (ចាប់ពីអនុប្រធានការិយាល័យរហូតដល់អគ្គនាយក) មាន ១ ៣៣៤ នាក់ ស្រី ២៧២ នាក់ ត្រូវជា ២០,៣៩ ភាគរយ។

អ្នកគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ (ចាប់ពីអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដល់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត) មាន ១ ៣១៤ នាក់ ស្រី ២០៥ នាក់ ត្រូវជា ១៦,៣៦ ភាគរយ។

នាយក នាយិកា នាយករង នាយិការងគ្រឹះស្ថានសិក្សា បឋមសិក្សា និងមធ្យមសិក្សាសរុប ១២ ៧២៣ នាក់ ស្រី ២ ១២៧ នាក់ ត្រូវជា ១៦,៧២ ភាគរយ។

ប្រកាសដាក់បុគ្គលិកអប់រំឱ្យចូលនិវត្តន៍ ១ ២២១នាក់ ស្រី ៦៦៧នាក់ (៥៤,៦២ ភាគរយ) ក្នុងនោះ ចូលនិវត្តន៍មុនកាលកំណត់ ១៦៨នាក់ ស្រី ៨៩នាក់ (៥២,៩៧ ភាគរយ)។

ប្រកាសតែងតាំងកម្មសិក្សាគ្រូចេញថ្មីគ្រប់កម្រិត ៣ ១៧៨នាក់ ស្រី ១ ៩២៧នាក់ (៦០,៦៣ភាគរយ) ក្នុងនោះ គ្រូមត្តេយ្យសិក្សា ២០០នាក់ ស្រី ១៩៤នាក់ (ស្មើ ៩៧ភាគរយ) គ្រូបឋមសិក្សា ១ ៦១៨នាក់ ស្រី ១ ០៥៣នាក់ (៦៥,០៨ភាគរយ) គ្រូបង្រៀនកម្រិតមូលដ្ឋាន ៧៥០នាក់ ស្រី ៣៦៩នាក់ (៤៩,២០ ភាគរយ) គ្រូបង្រៀនកម្រិតឧត្តម ៦១០នាក់ ស្រី ៣១១នាក់ (៥០,៩៨ភាគរយ)។

ស្នើតាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀន ៥ ៦៦៦នាក់ ស្រី ២ ៨៨៧ នាក់ (៥០,៩៥ភាគរយ) ក្នុងនោះ គ្រូបង្រៀនកម្រិតឧត្តមកម្មសិក្សា ៦៧៦នាក់ ស្រី ២៧៩នាក់ (៤១,២៧ភាគរយ) អតីតបុគ្គលិក ២៨៨នាក់ ស្រី ១០៣នាក់ (៣៣,៧៦ភាគរយ) តាមប្រព័ន្ធពន្លឿន ៩៩៦នាក់ ស្រី ៣៥១នាក់ (៣៥,២៤ ភាគរយ) គ្រូបង្រៀនកម្រិតមូលដ្ឋានកម្មសិក្សា ១៨៦នាក់ ស្រី ៥៤នាក់ (២៩,០៣ភាគរយ) អតីតបុគ្គលិក ១ ៥១៩នាក់ ស្រី ៧៦៤នាក់ (៥០,២៩ភាគរយ) និងគ្រូបង្រៀនកម្រិតបឋម ២ ០០១នាក់ ស្រី ១ ៣៣៦ នាក់ (៦៦ ៧៦ភាគរយ)។

ប្រកាសដំឡើងថ្នាក់ឋានន្តរស័ក្តិ ជូនគ្រូបង្រៀនទូទាំងប្រទេស ២៥ ៤៧២នាក់ ស្រី ១១ ៣៩៨នាក់ (៤៤,៧៤ ភាគរយ) ក្នុងនោះ ដំឡើងថ្នាក់ឋានន្តរស័ក្តិដោយព្រះរាជក្រឹត្យ ៤៤៧នាក់ ស្រី ៦៧ (១៤,៩៨ ភាគរយ) អនុក្រឹត្យ ២៨៨នាក់ ស្រី ៨៤នាក់ (២៩,១៦ ភាគរយ) និងដោយប្រកាស ២៤ ៧២៨នាក់ ស្រី ១១ ២៤៧នាក់ (៤៥,៤៨ ភាគរយ)។ ប្រកាសតែងតាំងអធិការអប់រំ ៤០នាក់ ស្រី ៤នាក់ (១០ ភាគរយ)។ ប្រកាសតែងតាំងមន្ត្រីគ្រប់គ្រង ១០៩នាក់ ស្រី ២៨នាក់ (២៥,៦៨ ភាគរយ)។

បំពាក់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំ ២ ០១០នាក់ ស្រី ៦៥១នាក់ (៣២,៣៩ ភាគរយ) ក្នុងនោះថ្នាក់ជាតិ ២៩៨នាក់ ស្រី ៧២នាក់ ស្មើ ២៤,១៦ភាគរយ ថ្នាក់ក្រោមជាតិ ១ ៧១២ នាក់ ស្រី ៥៧៩នាក់ ស្មើ ៣៨,៨២ភាគរយ។

ផ្តល់បណ្ណសរសើរដល់បុគ្គលិកអប់រំដែលមានស្នាដៃបំពេញការងារល្អក្នុងវិស័យអប់រំ យុវជន និង កីឡារហូតដល់ចូលនិវត្តន៍ ១ ០៨០នាក់ ស្រី ៥៨៥នាក់។

ផ្តល់ពានរង្វាន់ **សម្តេចតេជោសែន** ជូននាយកសាលាល្អ ៣នាក់ គ្រូបង្រៀនល្អ ៥នាក់ ស្រី ២នាក់ អ្នគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣ ចំនួន ៥នាក់ និងអ្នកគ្រូបង្រៀនល្អ គណិតវិទ្យា ថ្នាក់ទី១ ទី២ និងទី៣ ចំនួន ៥នាក់។

## ការពង្រឹងសមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំ

ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តលិខិតលេខ ១៤ អយក.សណ ចុះថ្ងៃអង្គារ ១០ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ស្តីពី ការលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ សំដៅយកចិត្តទុកដាក់ជ្រើសរើសមន្ត្រីរាជការស៊ីវិលជាស្ត្រីសម្រាប់បន្តវេនលើគ្រប់វិស័យអប់រំ ជាពិសេស នៅថ្នាក់ក្រោមជាតិ។

ការចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈផ្នែកកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល វិធីសាស្ត្របង្រៀនស្ទែម និងការគ្រប់គ្រងសាលារៀនរបស់គ្រូឧទ្ទេស ៣៦នាក់ ស្រី ១៣នាក់ នៅសិង្ហបុរី។

ការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនតាមបែបរិះរក ស្ថាបនាលើមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ការអភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើបញ្ញត្តិ និងការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យាដល់មន្ត្រី និងគ្រូឧទ្ទេសថ្នាក់ជាតិ ៤៩នាក់ ស្រី ២០នាក់ នៅសិង្ហបុរី។ ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ៥នាក់ ស្រី ១នាក់ នៅជប៉ុន។

ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសសាលាគរុកោសល្យនិងវិក្រឹតការខេត្តកម្រិតបរិញ្ញាបត្រ ៦៨នាក់ ស្រី ៣៣នាក់ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសថ្នាក់ជាតិលើ ១៥មុខវិជ្ជា នៅមធ្យមសិក្សា ១៤៣នាក់ ស្រី ៤១នាក់។

ការផ្តល់ឱកាសជូនបុគ្គលិកអប់រំទៅបន្តការសិក្សានៅក្រៅប្រទេស ៩៥នាក់ ស្រី ៤៧នាក់ (៤៩,៤៧ភាគរយ) ក្នុងនោះថ្នាក់ក្រោយបណ្ឌិត ២នាក់ ថ្នាក់បណ្ឌិត ២៦នាក់ ស្រី ១០នាក់ (៣៨,៤៦ភាគរយ) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ២៧នាក់ ស្រី ១៥នាក់ (៥៥,៥៥ ភាគរយ) ថ្នាក់បរិញ្ញាបត្រ ២២នាក់ ស្រី ១៤នាក់ (៦៣,៦៣ភាគរយ) និង វគ្គខ្លី ១៨នាក់ ស្រី ៨នាក់ (៤៤,៤៤ភាគរយ)។ បុគ្គលិកអប់រំមានឱកាសបានបន្តការសិក្សានៅក្នុងប្រទេស ៤៩៥ នាក់ ស្រី ១៦៥ នាក់(៣៣,៣៣ភាគរយ)។

ក្រសួងបានបញ្ជូនមន្ត្រី ៥ រូប ស្រី ៣ រូប ចូលរួមវគ្គបំប៉នថ្នាក់តំបន់ស្តីពី ការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំគ្រូបង្រៀន នៅតំបន់អាស៊ី-ប៉ាស៊ីភិកនៅប្រទេស អូបេគីស្ថាន។ ក្រសួងបានបញ្ជូនមន្ត្រីអប់រំ ឱ្យចូលរួមសិក្ខាសាលា សន្និសីទ វេទិការអប់រំ ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំកម្រិតជាតិ តំបន់ និងអន្តរជាតិជាច្រើន ដើម្បីអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ ដោយមានការចូលរួមពីស្ត្រីផងដែរ។

## ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាព

- ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាល នៃសាលាគរុកោសល្យទាំងអស់ចំនួន ១៥ម៉ោង
- ក្រសួងអប់រំ យុវជន និងកីឡា បានបន្តលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន សមត្ថភាពគ្រូបង្រៀន និងគន្លងអាជីពគ្រូបង្រៀន ដោយអភិវឌ្ឍសមត្ថភាពសាលាគរុកោសល្យ និងបានប្រែក្លាយទៅជា

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ដោយបានបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ១២ បូក ៤ សម្រាប់បឋមសិក្សា និងកម្រិតអប់រំមូលដ្ឋាន

- ក្រសួងអប់រំ យុវជន និងកីឡាបានលើកទឹកចិត្ត និងបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានដែលបង្រៀននៅវិទ្យាល័យតាមប្រព័ន្ធពន្លឿនដើម្បីឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តម ២ ៦៨៦នាក់ ស្រី ៩៣៤ នាក់ (៣៤,៧ ភាគរយ) និងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យទទួលបានបរិញ្ញាបត្រអប់រំ ៩៦៥នាក់ ២១៥នាក់ ស្រី ៣៨០នាក់ (៣៩,៤ ភាគរយ) ព្រមទាំងបណ្តុះបណ្តាលអធិការអប់រំថ្មី (ពីឆ្នាំ២០១៦-២០២០) បាន ៥ ជំនាន់ សរុប ២៤៧នាក់ ស្រី ២៥នាក់ (១០,១ ភាគរយ) និងអធិការអប់រំដែលមានស្រាប់ ៥១ នាក់ ស្រី ៥ នាក់ (៩,៨ ភាគរយ)។
- ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តបង្កើនគុណភាពនៃការបង្រៀនបន្ថែមទៀត ជាពិសេស មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ មន្ទីរពិសោធន៍ វិទ្យាសាស្ត្រ កុំព្យូទ័រ ភាសាបរទេស និងបណ្ណាល័យ តាមរយៈកម្មវិធីសាកល្បងសាលារៀនជំនាន់ថ្មី នៅតាមសាលាមធ្យមសិក្សា ដែលបានជ្រើសរើសនៅទូទាំងប្រទេស
- ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញវិធានការកំណែទម្រង់ការគ្រប់គ្រងបុគ្គលិក ដើម្បីឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល៥ឆ្នាំកន្លងមក ការអនុវត្តកម្មវិធីជាតិ និងវិធានការកំណែទម្រង់បានធ្វើឱ្យបុគ្គលិកអប់រំនៅទូទាំងប្រទេស មានការពេញចិត្ត និងបន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅគ្រប់ភូមិសិក្សាជាមួយនឹងការទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល តាមគ្រប់រូបភាពជាអាទិ៍៖ ការបើកបៀវត្សមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគារនិងបានទៀងទាត់នៅសប្តាហ៍ទី២ និងទី៤នៃខែនីមួយៗ បៀវត្សបុគ្គលិកអប់រំមានការកើនឡើង៣ដង គឺបៀវត្សអប្បបរមានៃបុគ្គលិកអប់រំកើនឡើងពី ៣១០ ០០០ រៀល ឆ្នាំ២០១៣ រហូតដល់ ១ ២០០ ០០០ រៀល នៅឆ្នាំ២០១៩ ប្រាក់លើកកម្ពស់ជីវភាពបុគ្គលិកអប់រំនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកកើនឡើងទ្វេដង និងប្រាក់កម្រៃបង្រៀនរបបម៉ោងបន្ថែមក៏មានការកើនឡើងទ្វេដងផងដែរ។ ប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូនត្រូវបានដំឡើងពីចំនួន ៦០០ ០០០ រៀល ទៅចំនួន ៨០០ ០០០ រៀល។
- គោលនយោបាយជាតិស្តីពី សុខភាពសិក្សាត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ឆ្នាំ២០១៩
- ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តកម្មវិធីសិក្សាបំណិនជីវិតសម្រាប់កម្រិតបឋមសិក្សា (ថ្នាក់ទី៥-៦) សាលាមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៨) សាលាមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១១) និងសម្រាប់យុវជនក្រៅសាលា។ កម្មវិធីសិក្សានេះមាននៅគ្រប់កម្រិតសិក្សាទាំងអស់ រួមមាន ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទកម្រិតមូលដ្ឋាន មេរោគអេដស៍/ជំងឺអេដស៍ អនាម័យ និងទស្សនៈយេនឌ័រ (ពីថ្នាក់ទី៥-៦) តួនាទីយេនឌ័រ លក្ខណៈភេទ ការសម្តែងចេញ

លក្ខណៈភេទ និងយេនឌ័រ (ពីថ្នាក់ទី៧-៨) និងសិទ្ធិមនុស្ស សមភាពយេនឌ័រ តួនាទីយេនឌ័រ ការបៀតបៀនផ្លូវភេទ និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (ពីថ្នាក់ទី១០-១១)

- ក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានផ្គត់ផ្គង់សៀវភៅបំណិនជីវិតចំនួន ៣៥០០ក្បាល ស្តីពីសុខភាពផ្លូវភេទ និងបន្តពូជសម្រាប់សិស្សថ្នាក់ទី៥-៦ និងបានបណ្តុះបណ្តាលគ្រូបឋមសិក្សាចំនួន ១ ៧៥៦នាក់ (ស្រី៥៩ ភាគរយ) នៅក្នុងខេត្តចំនួន៣។ ក្រសួងក៏បានផ្តល់ជូនសៀវភៅណែនាំបណ្តុះបណ្តាល និងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយរបៀបអនុវត្តកម្មវិធីសិក្សាបំណិនជីវិត ដែលផ្តោតលើសុខភាពផ្លូវភេទ និងបន្តពូជដល់គ្រូកម្រិតមធ្យមសិក្សាផងដែរ
- សៀវភៅណែនាំបណ្តុះបណ្តាលសម្រាប់យុវជន អំពីសមភាពយេនឌ័រ និងសិទ្ធិមនុស្ស ដែលមានចំណងជើងថា កញ្ចប់ឧបករណ៍សម្រាប់យុវជន បាននិងកំពុងប្រើប្រាស់នៅសាលារៀនសាធារណៈ ដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងស្វែងរកការគាំទ្ររបស់ក្រសួងកិច្ចការនារី ដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការចូលរួមរបស់ក្មេងស្រីក្នុងជីវភាពសង្គម សេដ្ឋកិច្ច និងនយោបាយ។

## ២.៣ បញ្ហាប្រឈម

- សាលារៀនមួយចំនួនមិនទាន់មានលទ្ធភាព និងសមត្ថភាពអនុវត្តការអប់រំស្វែម
- ផ្នត់គំនិតរបស់សង្គម ពាក់ព័ន្ធនឹងវិយរៀបអាពាហ៍ពិពាហ៍ និងបន្ទុកទទួលខុសត្រូវរបស់ស្ត្រីក្នុងគ្រួសារនៅតែចោទជាបញ្ហាទៅលើការធានាសមភាពនិងសមធម៌យេនឌ័រក្នុងវិស័យអប់រំ
- លទ្ធភាពបង្កើតគ្រឹះស្ថានឧត្តមសិក្សានៅតាមខេត្តមួយចំនួន ទាមទារឱ្យមានគ្រប់លក្ខខណ្ឌសមស្រប ដូចជា ៖ ប្រជាសាស្ត្រ គ្រូបង្រៀន ចំនួននិស្សិត
- ស្ត្រីក្នុងមុខតំណែងគ្រប់គ្រងវិស័យអប់រំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានចំនួនតិចនៅឡើយ
- ចំនួនអន្តេវាសិកដ្ឋានមិនទាន់ឆ្លើយតបទៅនឹងតម្រូវការស្នាក់នៅរបស់សិស្សស្រី និស្សិតនារី
- ចំណេះដឹងភាសាបរទេស បច្ចេកវិទ្យា និងកុំព្យូទ័ររបស់សិស្សបញ្ចប់ថ្នាក់ទី១២ មួយចំនួន នៅមានកម្រិត ដែលធ្វើឱ្យពួកគាត់ជួបការលំបាក ក្នុងការសិក្សានៅឧត្តមសិក្សា ជាពិសេសនៅឆ្នាំទី១ និងទី២
- និស្សិតនារីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាមានតិចនៅឡើយ
- កង្វះហេដ្ឋារចនាសម្ព័ន្ធនៅអង្គភាព និងគ្រឹះស្ថានសិក្សាមួយចំនួន ដូចជាបង្គន់អនាម័យស្តង់ដារ ប្រព័ន្ធទឹកស្អាត អគ្គិសនី អិនធឺណិត។

## ៣. ចក្ខុវិស័យ

លុបបំបាត់គម្លាតយេនឌ័រ ដើម្បីទាំងអស់គ្នាទទួលបានឱកាសពេញលេញ និងស្មើភាពពីសេវាអប់រំ។

## ៤. បេសកកម្ម

ផ្តល់លទ្ធភាពឱ្យកុមារ និងមនុស្សពេញវ័យទទួលបានអត្ថប្រយោជន៍ដូចគ្នា ទាំងការចុះឈ្មោះចូលរៀន ការបន្តការសិក្សា និងលទ្ធផលសិក្សានៅគ្រប់កម្រិតនិងគ្រប់ទិដ្ឋភាពនៅទូទាំងប្រទេសតាមរយៈ៖

- បង្កើនការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធ ដើម្បីធ្វើអន្តរាគមន៍ផ្នែកតម្រូវការ និងការកែលម្អគុណភាពអប់រំនៅគ្រប់កម្រិតទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ
- បង្កើនការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់ភាពអង់អាចដល់ស្ត្រីក្នុងវិស័យអប់រំ។

## ៥. គោលបំណង

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ មានគោលបំណង “ធានាឱ្យកុមារ និងមនុស្សពេញវ័យ ទទួលបានសេវាអប់រំប្រកបដោយសមភាព សមធម៌ បរិយាបន្ន និងសម្រេចបានលទ្ធផលសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព”។ ដើម្បីសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវគោលដៅចំនួនបីដូចខាងក្រោម ៖

- ធានាសម្រេចឱ្យបានសមភាពយេនឌ័រក្នុងការចូលរៀន និងរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ននៅគ្រប់សេវាអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ
- ធានាបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ
- ធានាកសាងបរិស្ថានអប់រំនិងបណ្តុះឥរិយាបថវិជ្ជមានរបស់សង្គមដើម្បីឆ្លើយតបទៅនឹងយេនឌ័រ។

## ៦. ក្របខណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ឆ្នាំ២០២១-២០២៥ ផ្តោតលើការដោះស្រាយរាល់ទម្រង់នៃការលំបាក និងឧបសគ្គដែលនាំឱ្យមានគម្លាត និងវិសមភាពយេនឌ័រក្នុងវិស័យអប់រំ។ ផែនការនេះបានអភិវឌ្ឍយុទ្ធសាស្ត្រ ដើម្បីធានាបានការសម្រេចសមភាពយេនឌ័រក្នុងវិស័យអប់រំ បង្កើនការចូលរួមបុគ្គលិកអប់រំជាស្ត្រីនៅក្នុងការគ្រប់គ្រងវិស័យអប់រំ និងកសាងឥរិយាបថវិជ្ជមានរបស់សង្គម ឆ្លើយតបនឹងយេនឌ័រ។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់នូវយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្ររងដូចខាងក្រោម ៖

### យុទ្ធសាស្ត្រទី ១៖ ស្រាវជ្រាវ ធ្វើការវិភាគ ផ្សព្វផ្សាយព័ត៌មាន និងលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ

#### យុទ្ធសាស្ត្ររង១.១៖ ស្រាវជ្រាវ និង វិភាគអំពីស្ថានភាពយេនឌ័រ

- ពង្រឹងការប្រមូលនិងគ្រប់គ្រងទិន្នន័យ និងព័ត៌មានស្តីពី តម្រូវការអប់រំ ស្ថានភាពកុមារ យុវជនក្នុងនិងក្រៅសាលា និងគុណភាពអប់រំ ជាពិសេសកុមារងាយរងគ្រោះ កុមារមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមារបាត់បង់ឱកាស
- សិក្សាស្រាវជ្រាវអំពីស្ថានភាពយេនឌ័រក្នុងវិស័យអប់រំ
- វិភាគយេនឌ័រក្នុងវិស័យអប់រំ។

យុទ្ធសាស្ត្ររង១.២ ៖ បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រ ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ

- ប្រមូលព័ត៌មាន និងអភិវឌ្ឍសម្ភារអប់រំ ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រតាមគ្រប់មធ្យោបាយ
- ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ លិខិតបទដ្ឋានគតិយុត្តនានា និងរបាយការណ៍វឌ្ឍនភាពដែលពាក់ព័ន្ធទៅនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី
- ផ្សព្វផ្សាយការយល់ដឹងអំពី ការប្រយុទ្ធប្រឆាំង ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធការធ្វើអាជីវកម្ម ពលកម្មលើស្ត្រី និងកុមារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ
- បង្កើតវេទិកាសំណួរ-ចម្លើយ ដើម្បីដោះស្រាយបញ្ហាស្ត្រីក្នុងវិស័យអប់រំ តាមរយៈទីប្រឹក្សាសាលារៀន វេទិកាផ្សេងៗ គេហទំព័របុគ្គលិកអប់រំជាស្ត្រី និងបណ្តាញទំនាក់ទំនងសង្គម។

យុទ្ធសាស្ត្ររង១.៣ ៖ លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ

- ធ្វើបច្ចុប្បន្នកម្មក្រុមការងារយេនឌ័រគ្រប់លំដាប់ថ្នាក់
- បញ្ចូលការអប់រំយេនឌ័រក្នុងគ្រប់កម្មវិធី គម្រោង សៀវភៅសិក្សាគោល ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ
- បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះការអប់រំកុមារី និងស្ត្រី និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បញ្ជ្រាបចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយរបាយការណ៍ អនុសញ្ញាស៊ីដ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាលើកុមារី និងស្ត្រី និងការប្រែប្រួលអាកាសធាតុស្តីពីផលប៉ះពាល់ សុវត្ថិភាព និងសុខភាពកុមារី និងស្ត្រីដល់គ្រប់អ្នកពាក់ព័ន្ធ។

## យុទ្ធសាស្ត្រទី ២៖ បញ្ចុះបញ្ចូល និងស្វែងរកការគាំទ្រ

យុទ្ធសាស្ត្ររង២.១ ៖ បញ្ចុះបញ្ចូល និងស្វែងរកការគាំទ្រ

- បង្កើតវេទិកា ដើម្បីស្វែងរកការគាំទ្រស្ត្រីឱ្យមានមុខតំណែង និងលើកកម្ពស់សមភាពយេនឌ័រក្នុងការងារដឹកនាំគ្រប់គ្រង
- ពង្រឹង និងពង្រីកសកម្មភាពទីប្រឹក្សាសាលារៀន ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជននៅតាមសាលារៀន
- ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អរបស់កុមារី ស្ត្រី ដែលមានស្នាដៃឆ្នើមថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី

- ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តលិខិតគតិយុតិស្តីពី ការតែងតាំងមន្ត្រីគ្រប់គ្រង ឱ្យឆ្លើយតប នឹងភាពជាអ្នកដឹកនាំស្ត្រីក្នុងមុខតំណែង។

### យុទ្ធសាស្ត្រទី២.២ ៖ បង្កើនកិច្ចសហការ និងការចូលរួម

- ផ្តល់ការគាំទ្រ ការលើកទឹកចិត្តដល់បុគ្គល និងអង្គភាពដែលមានស្នាដៃក្នុងការបំពេញការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ផ្តល់អាទិភាព និងឱកាសដល់បេក្ខជនជានារីនៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាល និង ជនជាតិដើមភាគតិចក្នុងការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់កម្រិត
- បង្កើនកិច្ចសហការជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រតែងតាំងមុខតំណែងស្ត្រីក្នុងការដឹកនាំគ្រប់គ្រងនៅគ្រប់កម្រិតនៃមុខតំណែងគ្រប់គ្រងរដ្ឋបាល និងគ្រឹះស្ថានសិក្សា
- លើកទឹកចិត្តកុមារី និងស្ត្រីឱ្យមានភាពអង់អាចលើការធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមចែករំលែកបទពិសោធន៍
- បង្កើនការចូលរួមរបស់សិស្សស្រី និងសិស្សមានពិការភាពលើគ្រប់សកម្មភាព
- លើកទឹកចិត្តបុរស និងស្ត្រីឱ្យចូលរួមគ្រប់សកម្មភាពអប់រំកាយនិងកីឡា នៅគ្រប់ផ្នែកទូទាំងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាពិសេសសិស្សស្រី
- ផ្តល់អាទិភាព និងឱកាសដល់គ្រូបង្រៀនជានារី ក្នុងការជ្រើសរើសប៉ុស្ត៍បម្រើការងារនៅស្រុកកំណើតរបស់ខ្លួនដែលជាតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល
- ផ្តល់ការគាំទ្រ និងជំរុញការចូលរួមយោបល់របស់នារីដែលជាសមាសភាពរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាវិន័យការិយាល័យអ.យ.កក្រុង ស្រុក ខណ្ឌ និងមន្ទីរអ.យ.ក
- ផ្តល់អាទិភាពលើបេក្ខភាពជានារី ជំនួសនារីដែលចូលនិវត្ត និងផ្លាស់ប្តូរទីកន្លែងបម្រើការងារ
- ចលនាសហគមន៍ ជាពិសេសការចូលរួមរបស់បុរស ក្នុងការថែទាំនិងអប់រំកូនដើម្បីផ្តល់ឱកាសដល់ស្ត្រីចូលរួមការងារសង្គម។

## យុទ្ធសាស្ត្រទី ៣៖ ពង្រឹងការអភិវឌ្ឍសមត្ថភាព

### យុទ្ធសាស្ត្រវង៣.១ ៖ វិភាគពីតម្រូវការអភិវឌ្ឍសមត្ថភាព

- សិក្សាស្រាវជ្រាវពីតម្រូវការអភិវឌ្ឍសមត្ថភាពយេនឌ័រក្នុងវិស័យអប់រំ
- កំណត់មុខសញ្ញាអាទិភាពសម្រាប់ទទួលការអភិវឌ្ឍសមត្ថភាព
- រៀបចំផែនការ កម្មវិធី និងខ្លឹមសារអភិវឌ្ឍសមត្ថភាពឱ្យឆ្លើយតបនឹងយេនឌ័រ
- ធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ក្នុង និងក្រៅប្រទេស។

### យុទ្ធសាស្ត្រវង៣.២ ៖បង្កើនសកម្មភាពអភិវឌ្ឍសមត្ថភាព

- បំប៉នសមត្ថភាពក្រុមការងារយេនឌ័រ និងមន្ត្រីអប់រំពាក់ព័ន្ធ អំពីយេនឌ័រ និងការធ្វើឱ្យរីកចម្រើនដល់អង្គភាព ក្នុងវិស័យអប់រំ
- បំប៉នសមត្ថភាពក្រុមការងារយេនឌ័រ ទីប្រឹក្សាសាលារៀន ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន យុវជនកាកបាទក្រហម និងយុវជនកាយរិទ្ធ តាមសាលារៀន និងសហគមន៍អំពីសមភាពយេនឌ័រក្នុងការអប់រំ
- បំប៉នមន្ត្រីគ្រប់គ្រង និងមន្ត្រីជំនាញអំពីការរៀបចំកម្មវិធី ការរៀបចំផែនការ វគ្គបំប៉ន កិច្ចប្រជុំ និងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រនៅគ្រប់កម្រិត
- បំប៉នសមត្ថភាពយុវជនក្នុងនិងក្រៅសាលារៀន បុគ្គលិកអប់រំជាស្ត្រីលើជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមក្នុងសកម្មភាពនានា
- បំប៉នសមត្ថភាពចំណេះដឹងយេនឌ័រដល់មន្ត្រីនៅតាមសហព័ន្ធកីឡាជាតិ
- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ ជាពិសេសស្ត្រីលើជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍
- បំប៉នអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី ផែនការសកម្មភាព ថវិកា និងការគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ឱ្យឆ្លើយតបទៅនឹងភាពឆាប់ចាប់អារម្មណ៍ទៅនឹងយេនឌ័រ
- បំប៉នមន្ត្រីអប់រំនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀនស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការអប់រំ
- បង្កើនចំណេះដឹងអំពីការងារយេនឌ័រក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ ការអប់រំបំណិនជីវិតមូលដ្ឋាន សុខភាពបន្តពូជ សុខភាពផ្លូវភេទ និងកម្មវិធីបណ្តុះបណ្តាលនានា
- បំប៉នសមត្ថភាពគ្រូឧទ្ទេស និងជនបង្គោលស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងការអប់រំគ្រូបង្រៀន។

## យុទ្ធសាស្ត្រទី៤ ៖ បញ្ជ្រាបយេនឌ័រក្នុងដំណើរការរៀន និងបង្រៀន

### យុទ្ធសាស្ត្ររង៤.១ ៖ បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងកម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាលគ្រូ

- បញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលនៅគ្រប់កម្រិតថ្នាក់ និងការអប់រំបច្ចេកទេស
- បញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស និងអប់រំក្រៅប្រព័ន្ធ
- បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាអប់រំក្រៅប្រព័ន្ធ
- បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងកម្មវិធីសិក្សា និងការស្រាវជ្រាវនៅឧត្តមសិក្សា
- បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងកម្មវិធីអប់រំយុវជនគ្រប់រូបភាព
- បញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីហាត់ហ្វឹកហ្វឺនកីឡាករ កម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- បញ្ចូលការអប់រំយេនឌ័រក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន។

### យុទ្ធសាស្ត្ររង៤.២ ៖ បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងសកម្មភាពរៀន និងបង្រៀន

- បំប៉នសមត្ថភាពគ្រូឧទ្ទេស ជនបង្គោល និងគ្រូបង្រៀនអំពីគរុកោសល្យឆ្លើយតបទៅនឹងភាពឆាប់ចាប់អារម្មណ៍យេនឌ័រ និងការអប់រំឆ្លើយតបនឹងសមភាពយេនឌ័រ
- បង្កើនសមត្ថភាពគ្រូបង្រៀនក្នុងការផលិតសម្ភារបង្រៀនសម្បូរបែប ដើម្បីជួយដល់ការបង្រៀន និងរៀនឆ្លើយតបទៅនឹងយេនឌ័រ
- បំប៉នអំពីវិធីសាស្ត្របង្រៀននិងរៀន ឆ្លើយតបនឹងសមភាពយេនឌ័រ
- បំប៉នសមត្ថភាពក្រុមការងារយេនឌ័រ គ្រូឧទ្ទេស នាយកសាលា និងគ្រូបង្រៀនស្តីពី ការអប់រំឱ្យជីវិតឆ្លើយតបនឹងយេនឌ័រ។

### យុទ្ធសាស្ត្ររង៤.៣ ៖ បញ្ជ្រាបយេនឌ័រក្នុងការដឹកនាំនិងការគ្រប់គ្រងអង្គភាពនិងសាលារៀន និងការរៀបចំបរិស្ថានអប់រំឆ្លើយតបនឹងយេនឌ័រ

- បំប៉នសមត្ថភាពស្តីពី ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងសាលារៀន ឆ្លើយតបនឹងសមភាពយេនឌ័រ
- បំប៉នសមត្ថភាពស្តីពី ការរៀបចំពិពណ៌នាមុខងារ ឆ្លើយតបនឹងយេនឌ័រ និងការធានាបាននូវសមភាពយេនឌ័រក្នុងបរិយាកាសការងារ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអង្គភាព សាលារៀនឆ្លើយតបនឹងយេនឌ័រ

- រៀបចំរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងអង្គភាព សាលារៀន និងថ្នាក់រៀនឆ្លើយតបនឹងយេនឌ័រ
- កែលម្អបរិស្ថានអង្គភាព សាលារៀនឆ្លើយតបនឹងយេនឌ័រ រួមទាំងផ្តល់កម្មវិធីអាហារូបត្ថម្ភ ទឹកស្អាត ជម្រាលសម្រាប់សិស្សមានពិការភាព បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងសម្ភារប្រើប្រាស់ផ្នែកអនាម័យ សម្រាប់បុគ្គលិកអប់រំជាស្ត្រី និងសិស្សស្រីដាច់ដោយឡែក។

## យុទ្ធសាស្ត្រទី៥ ៖ លើកកម្ពស់សកម្មភាពឆ្លើយតបនឹងយេនឌ័រ និងការពិនិត្យតាមដាន

### យុទ្ធសាស្ត្ររង៥.១ ៖ លើកកម្ពស់ការចូលរួម និងផ្តល់ភាពអង់អាចដល់កុមារី និងស្ត្រី

- បង្កើនចំនួនអាហារូបករណ៍នៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ជាពិសេសផ្តោតលើសិស្សស្រីនិងនិស្សិតនារី
- ផ្តល់អាហារូបករណ៍លើផ្នែកកីឡាដល់កុមារីដែលមានសមត្ថភាពតាមសាលារៀន និងអាចក្លាយជាកីឡាការិនីថ្នាក់ជាតិ
- ផ្តល់សេវាសុខាភិបាលសាធារណៈចាំបាច់ដល់សិស្សស្រីនិងបុគ្គលិកអប់រំជាស្ត្រី ដូចជាការចាក់ថ្នាំបង្ការនានា និងសេវាប្រឹក្សាយោបល់ផ្នែកសុខភាព ដោយឥតគិតថ្លៃ
- សហការជាមួយដៃគូ ក្នុងការផ្តល់ឥណទានសម្រាប់អ្នកបញ្ចប់ការបណ្តុះបណ្តាលជំនាញមុខរបរជាស្ត្រីនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍
- ផ្តល់អាហារូបករណ៍សម្រាប់ការអភិវឌ្ឍគុណវុឌ្ឍិបុគ្គលិកអប់រំ ជាពិសេសបុគ្គលិកអប់រំជាស្ត្រី
- ពង្រីកការបណ្តុះបណ្តាលមុខជំនាញងាយៗដល់ស្ត្រីនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍
- ជំរុញឱ្យសិស្ស និស្សិតនារីឱ្យចូលរៀនក្នុងការអប់រំស្វ័យ
- កែលម្អរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំឆ្លើយតបនឹងយេនឌ័រ។

### យុទ្ធសាស្ត្ររង៥.២ ៖ កសាងហេដ្ឋារចនាសម្ព័ន្ធ

- កសាងអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិត គរុសិស្ស គរុនិស្សិតជានារី និងផ្ទះស្នាក់នៅសម្រាប់គ្រូបង្រៀន ដាច់ដោយឡែក។

### យុទ្ធសាស្ត្ររង៥.៣ ៖ វិភាជន៍ថវិកាសម្រាប់ការងារបញ្ជ្រាបយេនឌ័រ

- សិក្សាអំពីប្រភពធនធានក្នុងការគាំទ្រដល់ការងារយេនឌ័រ
- រៀបចំផែនការថវិកាសម្រាប់អនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រនៅតាមអង្គភាពជំនាញ
- សហការជាមួយដៃគូអភិវឌ្ឍ ដើម្បីកៀរគរប្រភពធនធានសម្រាប់ការងារបញ្ជ្រាបយេនឌ័រ។

### យុទ្ធសាស្ត្ររង៥.៤ ៖ ពិនិត្យតាមដាន និងវាយតម្លៃ

- រៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងឧបករណ៍សម្រាប់ប្រមូលទិន្នន័យ
- ពិនិត្យតាមដាន និងវាយតម្លៃលើសកម្មភាពបញ្ជ្រាបយេនឌ័រ
- ពិនិត្យឡើងវិញលទ្ធផលការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំប្រចាំឆ្នាំ
- ពិនិត្យឡើងវិញលើការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ពាក់កណ្តាល និងចុងបញ្ចប់អាណត្តិ
- បោះពុម្ព និងផ្សព្វផ្សាយលទ្ធផលនៃការពិនិត្យឡើងវិញលើការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ។

## យុទ្ធសាស្ត្រទី៦ ៖ បង្កើនភាពជាដៃគូ

### យុទ្ធសាស្ត្ររង៦.១ ៖ ពង្រីកភាពជាដៃគូ

- បង្កើនភាពជាដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ក្នុងការគាំទ្រដល់ការផ្សព្វផ្សាយព័ត៌មានអប់រំយេនឌ័រគ្រប់រូបភាព ជាពិសេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយ
- សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មការយេនឌ័រថ្នាក់រាជធានី ខេត្ត គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងពង្រឹងទំនាក់ទំនងជាមួយយុវជនក្នុងប្រទេស និងក្រៅប្រទេស
- លើកកម្ពស់បណ្តាញស្ត្រីក្នុងសហគមន៍ ដើម្បីជួយពួកគាត់ក្នុងការរកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ។

### យុទ្ធសាស្ត្ររង៦.២ ៖ បង្កើនកិច្ចសហការនិងការគាំទ្រ

- បង្កើនកិច្ចសហការរវាងមន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលថ្នាក់ក្រុង ស្រុក និងសាលារៀន ជាមួយសហគមន៍ អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងមាតាបិតា ឬអ្នកអាណាព្យាបាលក្នុងការគាំទ្រសកម្មភាពបញ្ជ្រាបយេនឌ័រគ្រប់រូបភាព
- សហការជាមួយក្រសួងស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាក្នុងការគាំទ្រនិងស្វែងរកប្រភពធនធានសម្រាប់ការបញ្ជ្រាបយេនឌ័រ។

## ៧. ផែនការសកម្មភាព

### ៧.១ លទ្ធផលរំពឹងទុក

ការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥ ដើម្បីឈានទៅសម្រេចលទ្ធផលរំពឹងទុកដូចខាងក្រោម ៖




### ៧.២ សូចនាករ និងចំណុចដៅ

*តារាងទី៣ ៖ សូចនាករផលសម្រេច និងចំណុចដៅ ក្នុងការផ្តល់ឱកាសពេញលេញ និងស្មើភាពនៃការអប់រំប្រកបដោយគុណភាពសម្រាប់ស្ត្រី និងកុមារី*

| សូចនាករ | ឆ្នាំមូលដ្ឋាន | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
| សន្ទស្សន៍យុគភាពយេនឌ័រ | | | | | | |
| *អត្រាដុលនៃការសិក្សានៅបឋមសិក្សា* | 0.99 | 0.99 | 0.99 | 1.00 | 1.00 | 1.00 |
| *អត្រាពិតនៃការសិក្សានៅបឋមសិក្សា* | 1.01 | 1.01 | 1.01 | 1.00 | 1.00 | 1.00 |
| *អត្រាដុលនៃការសិក្សានៅម.បឋមភូមិ* | 1.18 | 1.15 | 1.11 | 1.08 | 1.04 | 1.01 |
| *អត្រាដុលនៃការសិក្សានៅម.ទុតិយភូមិ* | 1.30 | 1.25 | 1.19 | 1.14 | 1.08 | 1.03 |
| *អត្រាបញ្ចប់ការសិក្សានៅម.បឋមភូមិ* | 1.24 | 1.20 | 1.16 | 1.11 | 1.07 | 1.03 |
| *អត្រាបញ្ចប់ការសិក្សានៅម.ទុតិយភូមិ* | 1.27 | 1.22 | 1.17 | 1.13 | 1.08 | 1.03 |
| ភាគរយនិស្សិតស្រីចូលរៀននៅឧត្តមសិក្សា | 47.98 | 48.38 | 48.79 | 49.19 | 49.60 | 50.00 |
| អត្រាអក្ខរកម្មមនុស្សពេញវ័យ (ស្ត្រី) (១៥-១៩ឆ្នាំ) | 96.30 | 96.64 | 96.98 | 97.32 | 97.66 | 98.00 |

*តារាងទី៤ ៖ សូចនាករផលសម្រេច និងចំណុចដៅ ក្នុងការបង្កើនសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចក្លាហានដល់ស្ត្រីក្នុងការងារគ្រប់គ្រង*

| សូចនាករ | ឯកតា | ឆ្នាំមូលដ្ឋាន | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|
| | | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
| **ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រងនៅថ្នាក់កណ្តាល** | | | | | | | |
| - អគ្គនាយក សាកលវិទ្យាធិការ | % | 12.5 | 12.6 | 12.7 | 12.9 | 13.0 | 13.1 |
| - អគ្គនាយករង សាកលវិទ្យាធិការរង | % | 6.0 | 6.8 | 7.6 | 8.4 | 9.2 | 10.0 |
| - ប្រធាននាយកដ្ឋាន | % | 11.1 | 11.4 | 11.7 | 12.1 | 12.4 | 12.7 |
| - អនុប្រធាននាយកដ្ឋាន | % | 18.2 | 19.1 | 20.1 | 21.1 | 22.0 | 23.0 |
| - ប្រធានការិយាល័យ | % | 19.6 | 20.5 | 21.4 | 22.3 | 23.2 | 24.1 |
| - អនុប្រធានការិយាល័យ | % | 24.9 | 25.9 | 26.8 | 27.7 | 28.7 | 29.6 |
| **ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត** | | | | | | | |
| - ប្រធានមន្ទីរ | % | 4.0 | 5.2 | 6.4 | 7.6 | 8.8 | 10 |
| - អនុប្រធានមន្ទីរ | % | 23.5 | 24.3 | 25.2 | 26.0 | 26.8 | 27.6 |
| - ប្រធានការិយាល័យ | % | 12.9 | 13.4 | 14.0 | 14.6 | 15.1 | 15.7 |
| - អនុប្រធានការិយាល័យ | % | 23.4 | 24.2 | 25.0 | 25.8 | 26.5 | 27.3 |
| **ការចូលរួមរបស់ស្ត្រីក្នុងការងារគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ** | | | | | | | |
| - ប្រធានការិយាល័យ | % | 5.4 | 7.4 | 9.4 | 11.3 | 13.3 | 15.3 |
| - អនុប្រធានការិយាល័យ | % | 14.1 | 15.9 | 17.7 | 19.5 | 21.3 | 23.1 |
| **ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងនៅថ្នាក់សាលារៀន** | | | | | | | |
| - នាយិកា | % | 13.5 | 14.3 | 15.0 | 15.7 | 16.5 | 17.2 |
| - នាយិការង | % | 21.5 | 22.6 | 23.6 | 24.7 | 25.7 | 26.8 |
| **ភាគរយគ្រូបង្រៀនជាស្ត្រី** | | | | | | | |
| - ទូទាំងប្រទេស | % | 46.5 | 47.2 | 47.9 | 48.6 | 49.3 | 50.0 |
| - ទីប្រជុំជន | % | 51.7 | 53.4 | 55.0 | 56.7 | 58.3 | 60.0 |
| - ជនបទ | % | 44.8 | 45.8 | 46.9 | 47.9 | 49.0 | 50.0 |

## ៧.៣ ម៉ាទ្រិកលទ្ធផល សកម្មភាព

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព ចាប់ផ្តើម ២០២១ | ចំណុចដៅ ២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|
| **លទ្ធផល ១៖ នៅឆ្នាំ២០២៥ ឥរិយាបថវិជ្ជមានចំពោះការអប់រំកុមារី និងសមភាពយេនឌ័រ ក្នុងចំណោមអ្នកពាក់ព័ន្ធនឹងវិស័យអប់រំត្រូវបានបណ្តុះ** | | | | |
| លទ្ធផល១.១ ៖ ឧបសគ្គ និងរនាំងនៃការសិក្សារបស់សិស្សជាពិសេស សិស្សស្រី និងកុមារីត្រូវបានលុបបំបាត់ | | | | |
| យុទ្ធសាស្ត្រទី១ ៖ ស្រាវជ្រាវ ធ្វើការវិភាគ ផ្សព្វផ្សាយព័ត៌មាន និងការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ | ពង្រឹងការប្រមូល និងគ្រប់គ្រងទិន្នន័យនិងព័ត៌មានស្តីពីតម្រូវការអប់រំ ស្ថានភាពកុមារ យុវជន និងគុណភាពអប់រំ ជាពិសេសកុមារងាយរងគ្រោះ កុមារបាត់បង់ឱកាស និងកុមារជនជាតិដើមភាគតិច | ១០០% | របាយការណ៍លទ្ធផល ស្រាវជ្រាវ | ពអ ក្រយឌ |
| | សិក្សាស្រាវជ្រាវអំពីស្ថានភាពយេនឌ័រ ក្នុងវិស័យអប់រំ | ១០០% | របាយការណ៍លទ្ធផលស្រាវជ្រាវ | គប ក្រយឌ |
| | វិភាគយេនឌ័រក្នុងវិស័យអប់រំ | ១០០% | របាយការណ៍វិភាគយេនឌ័រក្នុងវិស័យអប់រំ | អគបផ ផក ក្រយឌ |
| | ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ លិខិតបទដ្ឋានគតិយុត្តនានា និងរបាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័រក្រសួង | បវ អង្គភាពពាក់ព័ន្ធ ក្រយឌ |
| | បញ្ចូលការអប់រំយេនឌ័រទៅក្នុងគ្រប់កម្មវិធីគម្រោង សៀវភៅសិក្សាគោល ផែនការសកម្មភាព គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័រក្រសួង អយក | អកស ផក អង្គភាពពាក់ព័ន្ធ |
| | បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះការអប់រំកុមារីនិងស្ត្រី និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | ៧០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័រក្រសួងអយក | អង្គភាពពាក់ព័ន្ធ |

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព<br>ចាប់ផ្តើម ២០២១ | ចំណុចដៅ<br>២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព<br>ទទួលខុសត្រូវ |
|---|---|---|---|---|
| យុទ្ធសាស្ត្រទី២ ៖ បញ្ចុះបញ្ចូល និង ស្វែងរកការគាំទ្រ | ពង្រឹង និងពង្រីកទីប្រឹក្សាសាលារៀន ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជននៅតាមសាលារៀន | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័រក្រសួង អយក | យជ បស មចទ |
| | លើកទឹកចិត្តកុមារី និងស្ត្រីឱ្យមានភាពអង់អាចលើការធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមចែករំលែកបទពិសោធន៍ | កុមារី ៦០%<br>ស្ត្រី ២០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័ររបស់ថ្នាក់មូលដ្ឋាន | បស អង្គភាពពាក់ព័ន្ធ |
| | បង្កើនការរួមចំណែករបស់សិស្សស្រីលើគ្រប់សកម្មភាព។ | ១០០% | របាយការណ៍វាយតម្លៃប្រចាំឆ្នាំ របាយការណ៍សាលារៀន | បស មចទ មន្ទីរអយក |
| យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងការអភិវឌ្ឍសមត្ថភាព | បំប៉នសមត្ថភាពក្រុមការងារយេនឌ័រ ទីប្រឹក្សាសាលារៀន ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន យុវជនកាកបាទក្រហម និងយុវជនកាយរិទ្ធិ តាមសាលារៀន និងសហគមន៍អំពីសមភាពយេនឌ័រក្នុងការអប់រំ | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័ររបស់ថ្នាក់មូលដ្ឋាន | អង្គភាពពាក់ព័ន្ធ |
| | បំប៉នសមត្ថភាពក្រុមការងារយេនឌ័រ និងមន្ត្រីអប់រំពាក់ព័ន្ធអំពីយេនឌ័រ និងការធ្វើឱ្យរីកចម្រើនដល់អង្គភាព ក្នុងវិស័យអប់រំ | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័ររបស់ថ្នាក់មូលដ្ឋាន | ក្រយឌ |
| | បំប៉នមន្ត្រីគ្រប់គ្រង និងមន្ត្រីជំនាញអំពីការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំកម្មវិធី ការរៀបចំផែនការ វគ្គបំប៉ន កិច្ចប្រជុំ និងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រនៅគ្រប់កម្រិត | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័ររបស់ថ្នាក់មូលដ្ឋាន | ក្រយឌ |
| | បង្កើនចំណេះដឹងអំពីការងារយេនឌ័រក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ ការអប់រំបំណិនជីវិតមូលដ្ឋានសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងកម្មវិធីបណ្តុះបណ្តាលនានា។ | ១០០% | របាយការណ៍វាយតម្លៃរបស់ក្រុមការងារយេនឌ័ររបស់ថ្នាក់មូលដ្ឋាន | អគយវ សស អកប |

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព ចាប់ផ្តើម ២០២១ | ចំណុចដៅ ២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|
| យុទ្ធសាស្ត្រទី៤ ៖ បញ្ជ្រាបយេនឌ័រក្នុងដំណើរការបង្រៀន និងរៀន | បញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលនៅគ្រប់កម្រិតថ្នាក់ និងការអប់រំបច្ចេកទេស | ៨០% | របាយការណ៍ពិនិត្យ និងវាយតម្លៃកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល | អគកស ក្រយឧ |
| | បញ្ជ្រាបខ្លឹមសារយេនឌ័រក្នុងកម្មវិធីអប់រំ យុវជនគ្រប់រូបភាព | ១០០% | របាយការណ៍ប្រចាំខែ ឆមាស និងឆ្នាំ | អគយវ |
| | បញ្ជ្រាបខ្លឹមសារយេនឌ័រទៅក្នុងកម្មវិធីហាត់ ហ្វឹកហ្វឺនកីឡាករ កម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា | ៤០% | របាយកាណ៍ពិនិត្យតាមដាននិងវាយតម្លៃការងារបញ្ជ្រាបយេនឌ័រ | អគកឡ |
| | បំប៉នសមត្ថភាពគ្រូឧទ្ទេសនិងគ្រូបង្រៀន អំពីគរុកោសល្យឆ្លើយតបទៅនឹងភាពឆាប់ចាប់អារម្មណ៍យេនឌ័រ | ៥០% | របាយការណ៍ប្រចាំឆ្នាំ | បវ ដៃគូអភិវឌ្ឍ អង្គភាពពាក់ព័ន្ធ |
| | កែលម្អបរិស្ថានអង្គភាព សាលារៀនឆ្លើយតបនឹងយេនឌ័រ រួមទាំងការផ្តល់ទឹកស្អាត បង្គន់ អនាម័យ និងសម្ភារបរិក្ខាផ្នែកអនាម័យសម្រាប់បុគ្គលិកអប់រំស្ត្រី សិស្សស្រី ដាច់ដោយឡែក។ | ៧០% | របាយការណ៍ប្រចាំឆ្នាំ | សស ពអ សណ |
| យុទ្ធសាស្ត្រទី៥ ៖ លើកកម្ពស់សកម្មភាពឆ្លើយតបនឹងយេនឌ័រ និងការពិនិត្យតាមដាន | បង្កើនចំនួនអាហារូបករណ៍នៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ជាពិសេសផ្តោតលើសិស្សស្រី និងនិស្សិតនារី | ៦០% | របាយការណ៍នាយកដ្ឋាន ពាក់ព័ន្ធ និងក្រុមការងារយេនឌ័រ | បស មចទ ឧស |
| | កសាងអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិត គរុសិស្ស គរុនិស្សិតជានារី និងផ្ទះស្នាក់នៅ សម្រាប់គ្រូបង្រៀន ដាច់ដោយឡែកពីគ្នា | ៥០% | របាយការណ៍របស់នាយកដ្ឋានពាក់ព័ន្ធ | សណ |
| | រៀបចំផែនការថវិកាសម្រាប់អនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រនៅតាមអង្គភាពជំនាញ។ | ១០០% | របាយការណ៍ហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធ | អង្គភាពពាក់ព័ន្ធ |

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព<br>ចាប់ផ្តើម ២០២១ | ចំណុចដៅ<br>២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព<br>ទទួលខុសត្រូវ |
|---|---|---|---|---|
| លទ្ធផល ១.២ ៖ ការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិតនៃការអប់រំត្រូវបានបង្កើន | | | | |
| យុទ្ធសាស្ត្រទី២ ៖ បញ្ច្រះបញ្ចូល និង ស្វែងរកការគាំទ្រ | បង្កើតវេទិកា ដើម្បីស្វែងរកការគាំទ្រស្ត្រីឱ្យមានមុខតំណែង និងលើកកម្ពស់សមភាពយេនឌ័រក្នុងការងារគ្រប់គ្រង | ៤៥% | របាយការណ៍ពិនិត្យឡើងវិញ ការងារបញ្ជ្រាបយេនឌ័រក្នុង វិស័យអប់រំ | បល |
| | ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អរបស់កុមារី ស្ត្រីដែលមានស្នាដៃឆ្នើម ថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី | ៧០% | | បល<br>អង្គភាពពាក់ព័ន្ធ |
| | ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តលិខិតគតិយុត្តិស្តីពី ការតែងតាំងមន្ត្រីគ្រប់គ្រងឱ្យឆ្លើយតបនឹងភាពជាអ្នកដឹកនាំស្ត្រីក្នុងមុខតំណែង | ១០០% | | បល ក្រយឌ<br>អង្គភាពពាក់ព័ន្ធ |
| | លើកទឹកចិត្តកុមារី និងស្ត្រីឱ្យមានភាពអង់អាច និងរួមចំណែក ក្នុងការចែករំលែកបទពិសោធន៍ និងការធ្វើសេចក្តីសម្រេចចិត្ត | ៨៥% | | អង្គភាពពាក់ព័ន្ធ |
| | បង្កើនការរួមចំណែករបស់សិស្សស្រីលើគ្រប់សកម្មភាព | ៩០% | | អង្គភាពពាក់ព័ន្ធ |
| | ចលនាសហគមន៍ ជាពិសេសការចូលរួមរបស់បុរស ក្នុងការថែទាំ និងអប់រំកូនដើម្បីផ្តល់ឱកាសដល់ស្ត្រីចូលរួមការងារសង្គម។ | ៨៥% | | អង្គភាពពាក់ព័ន្ធ |
| យុទ្ធសាស្ត្រទី៣ ៖ ពង្រឹង ការអភិវឌ្ឍសមត្ថភាព | បំប៉នសមត្ថភាពយុវជនក្នុងនិងក្រៅសាលាបុគ្គលិកអប់រំជាស្ត្រីលើជំនាញគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ ដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមក្នុងសកម្មភាពនានា | ៨៥% | របាយការណ៍ពិនិត្យឡើងវិញ ការងារបញ្ជ្រាបយេនឌ័រក្នុង វិស័យអប់រំ | យវ<br>បល |
| | អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ ជាពិសេសស្ត្រី លើជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ | ៨៥% | | បវព |
| | បង្កើនចំណេះដឹងអំពីការងារយេនឌ័រក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ ការអប់រំបំណិនជីវិតមូលដ្ឋាន | ៩៥% | | សស<br>តទវ |

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព<br>ចាប់ផ្តើម ២០២១ | ចំណុចដៅ<br>២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព<br>ទទួលខុសត្រូវ |
|---|---|---|---|---|
| | សុខភាពបន្តពូជ សុខភាពផ្លូវភេទ និងកម្មវិធីបណ្តុះបណ្តាលនានា។ | | | អង្គភាពពាក់ព័ន្ធ |
| យុទ្ធសាស្ត្រទី៤៖ បញ្ជ្រាបយេនឌ័រក្នុងដំណើរការបង្រៀន និងរៀន | បញ្ចូលការអប់រំយេនឌ័រក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន | ១០០% | របាយការណ៍ពិនិត្យឡើងវិញការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ | បវ ក្រយឧ |
| | បង្កើនសមត្ថភាពគ្រូបង្រៀនក្នុងការផលិតសម្ភារបង្រៀនសម្បូរបែបដើម្បីជួយដល់ការបង្រៀន និងរៀន ឆ្លើយតបទៅនឹងយេនឌ័រ។ | ៤០% | | បស មចទ<br>បវ |
| យុទ្ធសាស្ត្រទី៦ ៖ បង្កើនភាពជាដៃគូ | បង្កើនភាពជាដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ហើយបញ្ចុះបញ្ចូលពួកគេឱ្យគាំទ្រដល់ការផ្សព្វផ្សាយព័ត៌មានអប់រំយេនឌ័រគ្រប់រូបភាពជាពិសេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយ | ៧០% | របាយការណ៍ពិនិត្យឡើងវិញការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ | ផក បវ<br>អង្គភាពពាក់ព័ន្ធ |
| | លើកកម្ពស់បណ្តាញស្ត្រីក្នុងសហគមន៍ដើម្បីជួយពួកគាត់ក្នុងការរកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ។ | ៦៥% | របាយការណ៍វាយតម្លៃការងារបញ្ជ្រាបយេនឌ័រ | អកប |
| **លទ្ធផល ២ ៖ នៅឆ្នាំ២០២៥ សមភាពយេនឌ័រនៅក្នុងគ្រប់កម្រិតនៃការអប់រំ និងការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការងារគ្រប់គ្រងត្រូវបានបង្កើន** | | | | |
| លទ្ធផល ២.១ ៖ ចំនួនកុមារី ស្ត្រី និងកុមារា និង បុរស មានសមាមាត្រ ស្មើគ្នានៅគ្រប់កម្រិតនៃការអប់រំ | | | | |
| យុទ្ធសាស្ត្រទី៥ ៖ លើកកម្ពស់កម្មវិធី និងសកម្មភាពឆ្លើយតបនឹងយេនឌ័រ | បង្កើនចំនួនអាហារូបករណ៍នៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាសម្រាប់សិស្សក្រីក្រ ជាពិសេសផ្តោតលើសិស្សស្រីនិងនិស្សិតនារី | ៦០% ជានារី | របាយការណ៍របស់អង្គភាពជំនាញនិងដៃគូអភិវឌ្ឍ | បស មចទ<br>ឧស<br>ដៃគូអភិវឌ្ឍ |
| | ផ្តល់សេវាសុខាភិបាលសាធារណៈចាំបាច់ដល់សិស្សស្រី និងបុគ្គលិកអប់រំជាស្ត្រី ដូចជាការចាក់ថ្នាំបង្ការនានា និងសេវាប្រឹក្សាយោបល់ផ្នែកសុខភាពដោយឥតគិតថ្លៃ | ១០០% | របាយការណ៍របស់អង្គភាពជំនាញនិងដៃគូអភិវឌ្ឍ | សស |
| | ពង្រីកការបណ្តុះបណ្តាលមុខជំនាញងាយៗដល់ស្ត្រីនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍។ | ៦០% ជានារី | របាយការណ៍របស់អង្គភាពជំនាញនិងដៃគូអភិវឌ្ឍ | អកប<br>ដៃគូអភិវឌ្ឍ |

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព ចាប់ផ្តើម ២០២១ | ចំណុចដៅ ២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|
| លទ្ធផល ២.២ ៖ ស្ត្រី និងបុរស មានឱកាសស្មើគ្នា ក្នុងការទទួលបានការដំឡើងតួនាទី ឋានៈ ការបណ្តុះបណ្តាល និងការធ្វើសេចក្តីសម្រេច | | | | |
| យុទ្ធសាស្ត្រទី២ ៖ បញ្ចុះបញ្ចូល និង ស្វែងរកការគាំទ្រ | ការបញ្ចុះបញ្ចូល ស្វែងរកការគាំទ្រ | ស្ត្រីក្នុងការងារគ្រប់គ្រងត្រូវបានកើនឡើង ៖<br>- ថ្នាក់កណ្តាល កើន ១០%<br>- ថ្នាក់រាជធានី ខេត្ត កើន១០%<br>- ថ្នាក់ក្រុង ស្រុក ខណ្ឌ កើន១០%<br>- ថ្នាក់សាលារៀន កើន ១០%។ | ទិន្នន័យប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស | បលក្រយឌ |
| យុទ្ធសាស្ត្រទី៣ ៖ ពង្រឹង ការអភិវឌ្ឍសមត្ថភាព | ការវិភាគពីតម្រូវការអភិវឌ្ឍសមត្ថភាព | - ឯកសារស្តីពីស្ថានភាពនិងតម្រូវការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំត្រូវបានផលិត<br>- មុខសញ្ញាអាទិភាពថ្នាក់ជាតិ | របាយការណ៍វិភាគយេនឌ័រ របស់ក្រសួងអប់រំ យុវជន និងកីឡា | បលក្រយឌ |

| លទ្ធផល/យុទ្ធសាស្ត្រ | សកម្មភាព<br>ចាប់ផ្តើម ២០២១ | ចំណុចដៅ<br>២០២៥ | មធ្យោបាយផ្ទៀងផ្ទាត់ | អង្គភាព<br>ទទួលខុសត្រូវ |
|---|---|---|---|---|
| | | និងថ្នាក់ក្រោមជាតិ ១០០% ពិសេសនារី ត្រូវបានកំណត់ និងទទួលការបណ្តុះបណ្តាល<br>- ខ្លឹមសារអភិវឌ្ឍសមត្ថភាពយេនឌ័រ ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាព | | |
| | សកម្មភាពអភិវឌ្ឍសមត្ថភាព | - វគ្គបំប៉នសមត្ថភាព ត្រូវបានរៀបចំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- បូកសរុប និងពិនិត្យឡើងវិញការបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ។ | របាយការណ៍បូកសរុបការបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ<br>របាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ | ក្រយឧ<br>អង្គភាពថ្នាក់ជាតិ<br>មន្ទីរអេយក<br>រាជធានី ខេត្ត |

## ៧.៤ ម៉ាទ្រិកផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១-២០២៥

| ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
| **យុទ្ធសាស្ត្រទី ១៖ ស្រាវជ្រាវ ធ្វើការវិភាគ ផ្សព្វផ្សាយព័ត៌មាន និងការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ** | | | | |
| យុទ្ធសាស្ត្រង ១.១៖ ស្រាវជ្រាវ និងវិភាគអំពីស្ថានភាពយេនឌ័រ | | | | |
| • វិភាគយេនឌ័រក្នុងវិស័យអប់រំ (ក្រយឌ ផក)។ | • សិក្សាស្រាវជ្រាវអំពី ស្ថានភាពយេនឌ័រ ក្នុងវិស័យអប់រំ (ក្រយឌ បល)<br>• ពង្រឹងការប្រមូល និងគ្រប់គ្រងទិន្នន័យ និងព័ត៌មានស្តីពីតម្រូវការអប់រំ ស្ថានភាពកុមារ យុវជន និងគុណភាពអប់រំ (អអរ អគបផ)។ | • សិក្សាស្រាវជ្រាវអំពី ស្ថានភាពយេនឌ័រ ក្នុងវិស័យអប់រំ (ក្រយឌ បល)<br>• វិភាគយេនឌ័រក្នុងវិស័យអប់រំ (ក្រយឌ ផក)។ | • សិក្សាស្រាវជ្រាវអំពី ស្ថានភាពយេនឌ័រ ក្នុងវិស័យអប់រំ (ក្រយឌ បល)<br>• ពង្រឹងការប្រមូល និងគ្រប់គ្រងទិន្នន័យ និងព័ត៌មានស្តីពីតម្រូវការអប់រំ ស្ថានភាពកុមារ យុវជន និងគុណភាពអប់រំ (អគអរ អគបផ)។ | • សិក្សាស្រាវជ្រាវអំពី ស្ថានភាពយេនឌ័រ ក្នុងវិស័យអប់រំ (ក្រយឌ បល)<br>• វិភាគយេនឌ័រក្នុងវិស័យអប់រំ (ក្រយឌ ផក)។ |
| យុទ្ធសាស្ត្រង ១.២៖បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រ ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ | | | | |
| • ប្រមូលព័ត៌មាន និងអភិវឌ្ឍសម្ភារអប់រំ ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រតាមគ្រប់មធ្យោបាយ(បវ អកស)<br>• ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការ លិខិតបទដ្ឋាន គតិយុត្តនិង | • ប្រមូលព័ត៌មាន និងអភិវឌ្ឍសម្ភារអប់រំ ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រតាមគ្រប់មធ្យោបាយ(បវ អកស)<br>• ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការ លិខិតបទដ្ឋាន គតិយុត្ត និង | • ប្រមូលព័ត៌មាន និងអភិវឌ្ឍសម្ភារអប់រំ ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រតាមគ្រប់មធ្យោបាយ(បវ អកស)<br>• ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការ លិខិតបទដ្ឋាន គតិយុត្ត និង | • ប្រមូលព័ត៌មាន និងអភិវឌ្ឍសម្ភារអប់រំ ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រតាមគ្រប់មធ្យោបាយ(បវ អកស)<br>• ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការ លិខិតបទដ្ឋាន គតិយុត្ត និង | • ប្រមូលព័ត៌មាន និងអភិវឌ្ឍសម្ភារអប់រំ ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីយេនឌ័រតាមគ្រប់មធ្យោបាយ(បវ អកស)<br>• ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយ ផែនការ លិខិតបទដ្ឋាន គតិយុត្ត និង |

| ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
| របាយការណ៍លទ្ធផល ពាក់ព័ន្ធនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី (ក្រយឧ នក)<br>• ផ្សព្វផ្សាយការយល់ដឹងអំពី ការប្រយុទ្ធប្រឆាំង ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើស្ត្រី និងកុមារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ (នក ក្រយឧ)<br>• បង្កើតវេទិកាសំណួរ-ចម្លើយ ដើម្បីដោះស្រាយបញ្ហាស្ត្រីក្នុងវិស័យអប់រំ តាមរយៈទីប្រឹក្សាសាលារៀន វេទិកាផ្សេងៗ គេហទំព័របុគ្គលិកអប់រំជាស្ត្រី និងបណ្តាញទំនាក់ទំនងសង្គម (ក្រយឧ បល)។ | របាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី (ក្រយឧ នក)<br>• ផ្សព្វផ្សាយការយល់ដឹងអំពី ការប្រយុទ្ធប្រឆាំង ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើស្ត្រី និងកុមារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ (នក ក្រយឧ)<br>• បង្កើតវេទិកាសំណួរ-ចម្លើយ ដើម្បីដោះស្រាយបញ្ហាស្ត្រីក្នុងវិស័យអប់រំ តាមរយៈទីប្រឹក្សាសាលារៀន វេទិកាផ្សេងៗ គេហទំព័របុគ្គលិកអប់រំជាស្ត្រី និងបណ្តាញទំនាក់ទំនងសង្គម (ក្រយឧ បល)។ | របាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី (ក្រយឧ នក)<br>• ផ្សព្វផ្សាយការយល់ដឹងអំពី ការប្រយុទ្ធប្រឆាំង ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើស្ត្រី និងកុមារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ (នក ក្រយឧ)<br>• បង្កើតវេទិកាសំណួរ-ចម្លើយ ដើម្បីដោះស្រាយបញ្ហាស្ត្រីក្នុងវិស័យអប់រំ តាមរយៈទីប្រឹក្សាសាលារៀន វេទិកាផ្សេងៗ គេហទំព័របុគ្គលិកអប់រំជាស្ត្រី និងបណ្តាញទំនាក់ទំនងសង្គម (ក្រយឧ បល)។ | របាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី (ក្រយឧ នក)<br>• ផ្សព្វផ្សាយការយល់ដឹងអំពី ការប្រយុទ្ធប្រឆាំង ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើស្ត្រី និងកុមារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ (នក ក្រយឧ)<br>• បង្កើតវេទិកាសំណួរ-ចម្លើយ ដើម្បីដោះស្រាយបញ្ហាស្ត្រីក្នុងវិស័យអប់រំ តាមរយៈទីប្រឹក្សាសាលារៀន វេទិកាផ្សេងៗ គេហទំព័របុគ្គលិកអប់រំជាស្ត្រី និងបណ្តាញទំនាក់ទំនងសង្គម (ក្រយឧ បល)។ | របាយការណ៍លទ្ធផលពាក់ព័ន្ធនឹងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី (ក្រយឧ នក)<br>• ផ្សព្វផ្សាយការយល់ដឹងអំពី ការប្រយុទ្ធប្រឆាំង ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើស្ត្រី និងកុមារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងប្រយុទ្ធប្រឆាំងជំងឺផ្សេងៗ (នក ក្រយឧ)<br>• បង្កើតវេទិកាសំណួរ-ចម្លើយ ដើម្បីដោះស្រាយបញ្ហាស្ត្រីក្នុងវិស័យអប់រំ តាមរយៈទីប្រឹក្សាសាលារៀន វេទិកាផ្សេងៗ គេហទំព័របុគ្គលិកអប់រំជាស្ត្រី និងបណ្តាញទំនាក់ទំនងសង្គម (ក្រយឧ បល)។ |
| យុទ្ធសាស្ត្ររង ១.៣៖ លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ | | | | |
| • ធ្វើបច្ចុប្បន្នកម្មក្រុមការងារយេនឌ័រគ្រប់លំដាប់ថ្នាក់ | • បញ្ចូលការអប់រំយេនឌ័រក្នុងគ្រប់កម្មវិធី គម្រោង សៀវភៅ | • បញ្ចូលការអប់រំយេនឌ័រក្នុងគ្រប់កម្មវិធី គម្រោង សៀវភៅ | • បញ្ចូលការអប់រំយេនឌ័រក្នុងគ្រប់កម្មវិធី គម្រោង សៀវភៅ | • បញ្ចូលការអប់រំយេនឌ័រក្នុងគ្រប់កម្មវិធី គម្រោង សៀវភៅ |

| ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
| (ក្រយឌ បវ )<br>• បញ្ចូលការអប់រំយេនឌ័រក្នុងគ្រប់កម្មវិធី គម្រោង សៀវភៅសិក្សាគោល ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ (អកស នក បវ អកប វអក ឧស ក្រយឌ)<br>• បញ្ជ្រាបចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយរបាយការណ៍ អនុសញ្ញាសុី-ដ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាលើកុមារី និងស្ត្រី និងការប្រែប្រួលអាកាសធាតុស្តីពីផលប៉ះពាល់ សុវត្ថិភាព និងសុខភាពកុមារី និងស្ត្រីដល់គ្រប់អ្នកពាក់ព័ន្ធ(បវ បល នក ក្រយឌ)<br>• បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះកុមារី | សិក្សាគោល ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ (អកស នក បវ អកប វអក ឧស ក្រយឌ)<br>• បញ្ជ្រាបចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយរបាយការណ៍ អនុសញ្ញាសុី-ដ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាលើកុមារី និងស្ត្រី និងការប្រែប្រួលអាកាសធាតុស្តីពីផលប៉ះពាល់សុវត្ថិភាព និងសុខភាពកុមារី និងស្ត្រីដល់គ្រប់អ្នកពាក់ព័ន្ធ(បវ បល នក ក្រយឌ)<br>• បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះកុមារី និងស្ត្រី និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (បវ ក្រយឌ)។ | សិក្សាគោល ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ (អកស នក បវ អកប វអក ឧស ក្រយឌ)<br>• បញ្ជ្រាបចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយរបាយការណ៍ អនុសញ្ញាសុី-ដ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាលើកុមារី និងស្ត្រី និងការប្រែប្រួលអាកាសធាតុស្តីពីផលប៉ះពាល់សុវត្ថិភាព និងសុខភាពកុមារី និងស្ត្រីដល់គ្រប់អ្នកពាក់ព័ន្ធ(បវ បល នក ក្រយឌ)<br>• បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះកុមារី និងស្ត្រី និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (បវ ក្រយឌ)។ | សិក្សាគោល ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ (អកស នក បវ អកប វអក ឧស ក្រយឌ)<br>• បញ្ជ្រាបចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយរបាយការណ៍ អនុសញ្ញាសុី-ដ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាលើកុមារី និងស្ត្រី និងការប្រែប្រួលអាកាសធាតុស្តីពីផលប៉ះពាល់សុវត្ថិភាព និងសុខភាពកុមារី និងស្ត្រីដល់គ្រប់អ្នកពាក់ព័ន្ធ(បវ បល នក ក្រយឌ)<br>• បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះកុមារី និងស្ត្រី និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (បវ ក្រយឌ)។ | សិក្សាគោល ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងវិស័យអប់រំ (អកស នក បវ អកប វអក ឧស ក្រយឌ)<br>• បញ្ជ្រាបចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយរបាយការណ៍ អនុសញ្ញាសុី-ដ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាលើកុមារី និងស្ត្រី និងការប្រែប្រួលអាកាសធាតុស្តីពីផលប៉ះពាល់សុវត្ថិភាព និងសុខភាពកុមារី និងស្ត្រីដល់គ្រប់អ្នកពាក់ព័ន្ធ(បវ បល នក ក្រយឌ)<br>• បញ្ជ្រាបការលើកកម្ពស់ឥរិយាបថវិជ្ជមានចំពោះកុមារី និងស្ត្រី និងសមភាពយេនឌ័រនៅគ្រប់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (បវ ក្រយឌ)។ |

| ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
| និងស្ត្រី និងសមភាពយេនឌ័រ នៅគ្រប់អង្គភាពថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ (បវ ក្រយឧ)។ | | | | |
| **យុទ្ធសាស្ត្រទី ២៖ បញ្ជ្រាបញ្ចូល និងស្វែងរកការគាំទ្រ** | | | | |
| យុទ្ធសាស្ត្ររង ២.១៖ បញ្ជ្រាបញ្ចូល និងស្វែងរកការគាំទ្រ | | | | |
| • ពង្រឹងនិងពង្រីកសកម្មភាព ប្រឹក្សាសាលារៀន ក្រុមប្រឹក្សា កុមារ ក្រុមប្រឹក្សាយុវជននៅតាម សាលារៀន (អគយវ បវ ក្រយឧ)<br>• ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អរបស់ កុមារី ស្ត្រី ដែលមានស្នាដៃឆ្នើម ថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី (ក្រយឧ)<br>• ពិនិតឡើងវិញនិងពង្រឹងការ អនុវត្តលិខិតគតិយុត្តស្តីពី ការ តែងតាំងមន្ត្រីគ្រប់គ្រង ឆ្លើយតបនឹងភាពជាអ្នកដឹកនាំ ស្ត្រី (បល ក្រយឧ)។ | • បង្កើតវេទិកាដើម្បីស្វែងរក ការគាំទ្រស្ត្រី និងលើកកម្ពស់ សមភាពយេនឌ័រ ក្នុងការងារ ដឹកនាំគ្រប់គ្រង(ក្រយឧ បល)<br>• ពង្រឹងនិងពង្រីកសកម្មភាព ប្រឹក្សាសាលារៀន ក្រុមប្រឹក្សា កុមារ ក្រុមប្រឹក្សាយុវជននៅតាម សាលារៀន (អគយវ បវ ក្រយឧ)<br>• ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អ របស់ កុមារី ស្ត្រី ដែលមានស្នាដៃឆ្នើម ថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី (ក្រយឧ)។ | • ពង្រឹងនិងពង្រីកសកម្មភាព ប្រឹក្សាសាលារៀន ក្រុមប្រឹក្សា កុមារ ក្រុមប្រឹក្សាយុវជននៅតាម សាលារៀន ( យវ បវ ក្រយឧ )<br>• ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អ របស់ កុមារី ស្ត្រី ដែលមានស្នាដៃឆ្នើម ថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី (ក្រយឧ)។ | • បង្កើតវេទិកា ដើម្បីស្វែងរក ការគាំទ្រស្ត្រី និងលើកកម្ពស់ សមភាពយេនឌ័រ ក្នុងការងារ ដឹកនាំគ្រប់គ្រង(ក្រយឧ នា.បល)<br>• ពង្រឹងនិងពង្រីកសកម្មភាព ប្រឹក្សាសាលារៀន ក្រុមប្រឹក្សា កុមារ ក្រុមប្រឹក្សាយុវជននៅ តាមសាលារៀន (អគយវ បវ ក្រយឧ)<br>• ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អ របស់ កុមារី ស្ត្រី ដែលមានស្នាដៃឆ្នើម ថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី (ក្រយឧ)។ | • ពង្រឹងនិងពង្រីកសកម្មភាព ប្រឹក្សាសាលារៀន ក្រុមប្រឹក្សា កុមារ ក្រុមប្រឹក្សាយុវជននៅតាម សាលារៀន ( យវ បវ ក្រយឧ )<br>• ធ្វើយុទ្ធនាការសមភាពយេនឌ័រ ដោយបង្ហាញពីគំរូល្អ របស់ កុមារី ស្ត្រី ដែលមានស្នាដៃឆ្នើម ថ្នាក់ដឹកនាំជាស្ត្រី និងវីរនារី (ក្រយឧ)។ |

| ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
| យុទ្ធសាស្ត្ររង ២.២៖ បង្កើនកិច្ចសហការ និងការចូលរួម | | | | |
| • ផ្តល់អាទិភាព និងឱកាស ដល់បេក្ខជនជានារីនៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាល និងជនជាតិ ដើមភាគតិចក្នុងការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់កម្រិត (បវ បល)<br>• បង្កើនកិច្ចសហការជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រ តែងតាំង មុខតំណែងស្ត្រីក្នុងការដឹកនាំគ្រប់គ្រងនៅគ្រប់កម្រិតនៃមុខតំណែងគ្រប់គ្រងរដ្ឋបាល និងគ្រឹះស្ថានសិក្សា (មន្ទីរអេយក)<br>• លើកទឹកចិត្តកុមារី និងស្ត្រីឱ្យមានភាពអង់អាចលើការធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមចែករំលែកបទពិសោធន៍ (អង្គ.ពាក់ព័ន្ធ) | • ផ្តល់ការគាំទ្រ ការលើកទឹកចិត្តដល់បុគ្គលនិងអង្គភាពដែលមានស្នាដៃក្នុងការបំពេញការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ក្រយឌ បល)<br>• ផ្តល់អាទិភាព និងឱកាសដល់បេក្ខជនជានារីនៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាលនិងជនជាតិដើមភាគតិចក្នុងការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់កម្រិត (បវ បល)<br>• លើកទឹកចិត្តកុមារី និងស្ត្រីឱ្យមានភាពអង់អាចលើការធ្វើសេចក្តីសម្រេចចិត្ត និងចូលរួមចែករំលែកបទពិសោធន៍ (អង្គ.ពាក់ព័ន្ធ)<br>• លើកទឹកចិត្តបុរស និងស្ត្រីឱ្យចូលរួមគ្រប់សកម្មភាពអប់រំកាយនិងកីឡានៅគ្រប់ផ្នែក | • ផ្តល់ការគាំទ្រ ការលើកទឹកចិត្តដល់បុគ្គលនិងអង្គភាព ដែលមានស្នាដៃក្នុងការបំពេញការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(ក្រយឌ បល)<br>• ផ្តល់អាទិភាព និងឱកាសដល់បេក្ខជនជានារីនៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាលនិងជនជាតិដើមភាគតិចក្នុងការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់កម្រិត (បវ បល)<br>• បង្កើនកិច្ចសហការជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការគាំទ្រ តែងតាំងមុខតំណែងស្ត្រីក្នុងការដឹកនាំគ្រប់គ្រងនៅគ្រប់កម្រិតនៃមុខតំណែងគ្រប់គ្រងរដ្ឋបាល និងគ្រឹះស្ថានសិក្សា (មន្ទីរអេយក) | • ផ្តល់ការគាំទ្រ ការលើកទឹកចិត្តដល់បុគ្គល និងអង្គភាពដែលមានស្នាដៃក្នុងការបំពេញការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(ក្រយឌ បល)<br>• ផ្តល់អាទិភាព និងឱកាសដល់បេក្ខជនជានារីនៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាលនិងជនជាតិដើមភាគតិចក្នុងការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់កម្រិត (បវ បល)<br>• បង្កើនកិច្ចសហការជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រ តែងតាំងមុខតំណែងស្ត្រីក្នុងការដឹកនាំគ្រប់គ្រងនៅគ្រប់កម្រិតនៃមុខតំណែងគ្រប់គ្រងរដ្ឋបាល និងគ្រឹះស្ថានសិក្សា (មន្ទីរអេយក) | • ផ្តល់ការគាំទ្រ ការលើកទឹក ចិត្តដល់បុគ្គលនិងអង្គភាព ដែលមានស្នាដៃក្នុងការបំពេញការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(ក្រ.យឌ នា.បល)<br>• ផ្តល់អាទិភាព និងឱកាសដល់បេក្ខជនជានារីនៅតំបន់ជួបការលំបាក តំបន់ដាច់ស្រយាលនិងជនជាតិដើមភាគតិចក្នុងការប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់កម្រិត (បវ បល)<br>• បង្កើនកិច្ចសហការជាមួយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រ តែងតាំងមុខតំណែងស្ត្រីក្នុងការដឹកនាំគ្រប់គ្រងនៅគ្រប់កម្រិតនៃមុខតំណែងគ្រប់គ្រងរដ្ឋបាល និងគ្រឹះស្ថានសិក្សា (មន្ទីរអេយក) |

| ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|
